**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Deoit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា. ណែម យ៉ុងអ៊ី**
**កញ្ញា. ជា ស្រីល័ក្ខ**

សាស្ត្រាចារ្យណែនាំ
**សាស្ត្រាចារ្យ ហោ សុភ័ណ្ណ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ណែម យ៉ុងអ៊ី** និងនាងខ្ញុំឈ្មោះ **ជា ស្រីល័ក្ខ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត** ជំនាន់ទី ២១ ឆ្នាំសិក្សា២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមគោរពលំអោនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញុតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

- លោកឪពុក **ប៉ុល ហេម** - លោកឪពុក **ជា គីម**
- អ្នកម្តាយ **វ៉ាន់ ខិន** - អ្នកម្តាយ **ខាត់ ចន្ថា**

ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅ និងឧបត្ថមគ្រប់បែបយ៉ាងដល់រូបកូនៗទាំងស្មារតី និងសម្ភារៈ ជាពិសេសរួមទាំងការផ្តល់នូវដំបូន្មានដ៏ល្អរបស់លោកដល់រូបកូនចាប់តាំងពីពេលកូននៅកុមារភាព រហូតដល់កូនធំពេញវ័យ និងបានផ្តល់ឱកាសអោយកូនទទួលបានការបណ្តុះបណ្តាលតាំងពីថ្នាក់មត្តេយ្យសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា ដើម្បីឲ្យកូនៗក្លាយជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អ។ លោកអ៊ុំ លោកពូ អ្នកមីង បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី ទាំងអស់ដែលបានជួយទំនុកបំរុងទាំងផ្នែកស្មារតី ដោយផ្តល់នូវការលើទឹកចិត្ត និងថវិការដល់រូបយើងខ្ញុំឲ្យខិតខំប្រឹងប្រែងរៀនសូត្រ រហូតឈានដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកបរិញ្ញាបត្រនីតិសាស្រ្តដល់សព្វថ្ងៃនេះ។

- ឯកឧត្តម **លុយ ចន្ធូរ៉ា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក-លោកស្រីសាស្រ្តចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងបានជួយជ្រោមជ្រែងតម្រង់ទិសពួកយើងខ្ញុំ តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តនេះប្រកបដោយក្រមវិជ្ជាជីវៈ។

- លោកសាស្រ្តចារ្យ **ហោ សុវ័ណ្ណ** ដែលជាសាស្រ្តាចារ្យណែនាំ ដើម្បីធ្វើឲ្យដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយជោគជ័យ។ លោកសាស្រ្តាចារ្យបានចំណាយទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ផ្តល់ជាអនុសាសន៍ល្អៗ និងជួយកែលម្អនូវចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឲ្យសារណាយើងខ្ញុំទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមធ្វើការអរគុណ និងដឹងគុណម្តងទៀតដល់អ្នកមានគុណទាំងពួងដូចដែលបានរៀបរាប់ខាងលើ សូមបានប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណរគុណ**

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រ ដើម្បីទទួលបាននូវចំណេះដឹងពីលោក-លោកស្រីសាស្ត្រាចារ្យក្នុងសាកលវិទ្យាល័យនាងខ្ញុំឈ្មោះ **ណែម យ៉ុងអ៊ី** និងនាងខ្ញុំឈ្មោះ **ជា ស្រីល័ក្ខ** ត្រូវបានលើកទឹកចិត្ត និងទទួលការអនុញ្ញាតិពីសាកលវិទ្យាល័យ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ ″**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**″។

ដោយសារតែមានចម្ងល់ និងការចង់ដឹងឲ្យកាន់តែស៊ីជម្រៅអំពីកិច្ចការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជន។ សារណាមួយនេះ ផ្តោតសំខាន់ទៅលើសិទ្ធិ និងករណីកិច្ចរបស់អនីតិជនក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះមុខច្បាប់ ព្រមជាមួយនឹងនីតិវិធីអនុវត្តលើអនីតិជន ដែលធ្វើយ៉ាងណាធានាដល់ឧត្តមប្រយោជន៍របស់អនីតិជន។ លើសពីនេះទៅទៀត សារណាមួយនេះអាចលេចចេញជារូបរាងឡើងក៏ដោយសារមានការជួយជ្រោមជ្រែង ណែនាំតម្រង់ទិសពីសំណាក់សាស្ត្រាចារ្យ **ហោ សុភ័ណ្ឌា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗ សម្រាប់ជាប្រទីប និងជាយានដល់យើងខ្ញុំ។

ទោះបីជាយើងខ្ញុំបានធ្វើការពិនិត្យផ្ទៀងផ្ទាត់ការស្រាវជ្រាវមួយនេះយ៉ាងយកចិត្តទុកដាក់យ៉ាងណាក៏នៅតែអាចនឹងមានកំហុសឆ្គងកើតមានឡើងជាពុំខាន។ ដូចនេះ យើងខ្ញុំសូមធ្វើការអភ័យទោសនូវរាល់កំហុសឆ្គងដែលអាចនឹងកើតឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយយើងខ្ញុំរងចាំទទួលនូវការរិះគន់ និងការកែលម្អក្នុងន័យស្ថាបនា ដើម្បីអាចធ្វើឲ្យស្នាដៃបន្តបន្ទាប់ទៀតកាន់តែមាននូវភាពប្រសើរឡើង។

ជាចុងបញ្ចប់ ក្នុងនាមយើងខ្ញុំជាអ្នកសរសេរសារណានេះ ក៏សង្ឃឹមថាសារណាមួយនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទាន ព្រមទាំងផ្តល់ជាចំណេះដឹងបន្ថែមសម្រាប់ជាគន្លះ និងជំនួយស្មារតីដល់សិស្សប្អូនជំនាន់ក្រោយៗទៀតក្នុងការសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែកដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ជាបន្តបាន។ ហើយយើងខ្ញុំទាំងពីររូបក៏សូមជូនពរដល់បងប្អូនអ្នកអាន និស្សិត និងអស់លោក-លោកស្រីដែលកំពុងអានសៀវភៅមួយនេះ សូមទទួលបានជោគជ័យគ្រប់ភារកិច្ច សុខសុវត្ថិភាពសម្រាប់ការធ្វើដំណើរទាំងជិតឆ្ងាយ និងទទួលបាននូវសុភាពល្អជៀសផុតពីជំងឺដ៏កាចសាហាវ កូវីត-១៩។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

**ផ្នែកទី១៖ លក្ខខណ្ឌអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** ........ ៣

១.អនីតិជនមានអាយុក្រោម ១៤ ឆ្នាំ ........ ៤

២.អនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........ ៥

**ផ្នែកទី២៖ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន** ........ ៦

១.កាលៈទេសៈនៃបទល្មើស ........ ៦

២.បុគ្គលិកលក្ខណៈរបស់អនីតិជន ........ ៧

**ជំពូកទី២**

**លំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន**

**ផ្នែកទី១៖ ដំណាក់កាលនគរបាលយុត្តិធម៌** ........ ៨

១.ការចាប់ខ្លួនអនីតិជនដែលប្រព្រឹត្តបទល្មើស ........ ៩

២.ការឆែកឆេរ ........ ៩

៣.ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស ........ ១០

៤.ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន ........ ១១

៥.នីតិវិធីនៃការស្តាប់ចម្លើយ ........ ១២

៦.កំណត់ហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន ........ ១៣

**ផ្នែកទី២៖ ដំណាក់កាលអង្គការអយ្យការ** ........ ១៣

១.សមត្ថកិច្ចរបស់អង្គការអយ្យការ និងការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ........ ១៤

២.នីតិវិធីនៃការស្តាប់ចម្លើយ ........ ១៤

៣.ការបង្វែរ ........ ១៥

៣.១ លក្ខខណ្ឌអប្បបរមានៃការបង្វែរ ........ ១៦

៣.២ លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ ........ ១៦

៣.៣ នីតិវិធីនៃការបង្វែ ........ ១៧

៣.៤ ការទទួលបន្ទុកក្នុងការបង្វែរ ........ ១៨

**ផ្នែកទី៣៖ ដំណាក់កាលចៅក្រមស៊ើបសួរ** ........................................ ១៨
១.តួនាទីរបស់ចៅក្រមស៊ើបសួរ ........................................ ១៨
១.១ សមត្ថកិច្ចនៃការស៊ើបសួរ ........................................ ១៨
១.២ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ........................................ ១៨
១.៣ នីតិវិធីនៃការស្តាប់ចម្លើយ ........................................ ១៩
២.អំណាចរបស់ចៅក្រមស៊ើបសួរ ........................................ ២០
៣.អំណាចក្នុងការបង្វែរ ........................................ ២០
៤.ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ........................................ ២០
៥.ការដោះលែងឲ្យនៅក្រៅឃុំ ........................................ ២២
**ផ្នែកទី៤៖ ដំណាក់កាលសវនាការ(ចៅក្រមជំនុំជម្រះ)** ........................................ ២៣
១.សមត្ថកិច្ចរបស់តុលារការជាន់ទាប ........................................ ២៣
២.សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់ ........................................ ២៤

## ជំពូកទី៣
## ការអនុវត្តទោសចំពោះអនីតិជន

**ផ្នែកទី១៖ ការអនុវត្តទោសពិន័យចំពោះអនីតិជន** ........................................ ២៦
១.ការដាស់តឿនឲ្យបង់ប្រាក់ពិន័យ ........................................ ២៦
២.ការរួចផុតពីការបង្ខំដល់រូបកាយ ........................................ ២៧
**ផ្នែកទី២៖ ការអនុវត្តទោសដាក់ពន្ធនាគារចំពោះអនីតិជន** ........................................ ២៧
១.ការអនុវត្តទោសចំពោះអនីតិជនអាយុក្រោម ១៤ ឆ្នាំ ........................................ ២៨
២.ការអនុវត្តទោសចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........................................ ២៩
**សេចក្តីសន្និដ្ឋាន** ........................................ ៣១
**អនុសាសន៍** ........................................ ៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នីតិវិធីព្រហ្មទណ្ឌ គឺជាបណ្តុំនៃវិធានដែលកំណត់ពីបុគ្គលិកលក្ខណៈរបស់ចារី និងសកម្មភាពរបស់តុលាការព្រហ្មទណ្ឌចាប់តាំងពីពេលដែលមានការសង្ស័យពីការប្រព្រឹត្តបទល្មើស រហូតដល់ពេលដែលចារីត្រូវបានកំណត់អត្តសញ្ញាណ ធ្វើការឃាត់ខ្លួន ឃុំខ្លួនបណ្តោះអាសន្ន និងធ្វើការជំនុំជម្រះផ្តន្ទាទោស។ បុគ្គលដែលប្រព្រឹត្តបទល្មើសអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ រូបវន្តបុគ្គលចែកចេញជាពីរគឺ នីតិជន និងអនីតិជន។ **នីតិជន** សំដៅលើជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ រីឯ **អនីតិជន** គឺសំដៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ យើងដឹងហើយថាអនីតិជនគឺជាជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលអនីតិជនទូទៅតែងតែមានការការពារពីច្បាប់ ប៉ុន្តែបើអនីតិជនបានប្រព្រឹត្តខុសនឹងច្បាប់ហើយមានអាយុលើសពី ១៤ (ដប់បួន) ឆ្នាំ នោះអនីតិជនក៏អាចត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ មនុស្សម្នាក់ត្រូវចាត់ទុកថាមានសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើពេលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះបានឈានដល់កម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ការកំណត់អំពីការកម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ នឹងបង្កើតបានទៅជាមូលដ្ឋានផ្នែកគតិយុត្តិមួយ សម្រាប់កំណត់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជនផ្ទាល់តែម្តង។ កម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនក៏មានការប្រែប្រួលទៅតាមប្រទេសផ្សេងៗគ្នា ដោយយោងទៅតាមលក្ខណៈពិសេសនៃនយោបាយព្រហ្មទណ្ឌ ការរីកចម្រើនផ្នែករាងកាយ និងប្រាជ្ញាស្មារតីរបស់អនីតិជននោះផងដែរ។

បើពិនិត្យមើលទៅលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រង់បញ្ញត្តិនៃមាត្រា ៣៨ បានចែងថា“**នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់កម្រិតអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ**”។ ប៉ុន្តែ តុលាការក៏អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។

ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយសង្កេតឃើញថា អនីតិជនជាជនដែលមានសមត្ថភាពយល់ដឹងខាងអំពើនូវមានកម្រិតនៅឡើយ ដូច្នេះ ទើបមាននូវសំណួរចោទសួរឡើងថា តើអាយុ ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជន ឬយ៉ាងណា? ក្រៅពីនេះ ដោយហេតុថា អនីតិជនជាជនដែលមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិតយ៉ាងដូច្នេះ តើគួរប្រើប្រាស់នូវវិធានការណាខ្លះចំពោះពួកគាត់នៅពេលដែលពួកគាត់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ? ជាមួយគ្នានេះដែរ តើគួរឲ្យមាននូវការអនុវត្តនីតិវិធីពិសេសមួយចំពោះពួកគាត់ ដែរឬទេ? ចុះចំពោះការអនុវត្តទោសវិញ តើនឹងប្រព្រឹត្តទៅមានលក្ខណៈយ៉ាងណាដែរ? ដោយសារតែមាននូវចំណោទបញ្ហាគតិយុត្តិទាំងអស់នេះហើយ ទើបនៅក្នុងការសិក្សាស្រាវជ្រាវសារណារបស់យើងខ្ញុំ បានធ្វើការសម្រេចចិត្តយ៉ាងមុតមាំថា ត្រូវតែ

ជ្រើសរើសយកនូវប្រធានបទស្តីពី"**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**" នេះឡើងមកសរសេរគឺ ក្នុងន័យ ដើម្បីស្រាយនូវចម្ងល់ដែលបានចោទសួរខាងលើនេះ។ **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** សំដៅដល់ការទទួលទណ្ឌកម្មព្រហ្មទណ្ឌរបស់អនីតិជនចំពោះ បទល្មើសដែលខ្លួនបានប្រព្រឹត្តឡើង។ ពាក្យថា ទណ្ឌកម្មព្រហ្មទណ្ឌក្នុងន័យនេះ គឺសំដៅដល់ការប្រកាសផ្តន្ទាទោសដែលធ្វើឡើងដោយស្ថាប័នតុលាការផ្ទាល់តែម្តង។ មានន័យថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន គឺជាគោលការណ៍មួយដែលបានធ្វើការកំណត់ពាក់ព័ន្ធនឹងអំពើនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននេះឯង។

នៅក្នុងការសិក្សាស្រាវជ្រាវសរសេរសារណានេះដែរ គឺធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់អំពីភាពមិនច្បាស់លាស់មួយចំនួន ក៏ដូចជាចង់ស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តិដូចដែលបានលើកឡើងខាងលើស្រាប់ឲ្យបានកាន់តែស៊ីជម្រៅ។ លើសពីនេះទៅទៀត គឺដើម្បីពង្រឹង និងពង្រីកនូវសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌនេះ។ ហើយចំពោះសមិទ្ធផល ដែលបានមកពីការសិក្សាស្រាវជ្រាវនេះ ក៏ជាផ្នែកមួយនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍនូវវិស័យព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ។

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសរើសឯកសារជាមូលដ្ឋានមួយចំនួនដើម្បីសរសេរសារណានេះឡើង។ ឯកសារទាំងនោះរួមមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣, អនុសញ្ញាស្តីពីសិទ្ធិកុមារ, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ និងរួមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀត ដូចដែលបានលើកឡើងនៅក្នុងឯកសារយោង។

នៅក្នុងការសរសេរសារណានេះ គឺបានលើកឡើងតែពីការពាក់ព័ន្ធទាំងឡាយណាដែលទាក់ទងជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន នីតិវិធីដែលត្រូវយកមកអនុវត្តចំពោះអនីតិជន និងទោសដែលអនីតិជនត្រូវទទួលតែប៉ុណ្ណោះ។ សារណានេះ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពិពណ៌នា។ យើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវដោយធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីឲ្យកាន់តែមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។ ព័ត៌មានទាំងឡាយត្រូវបានជ្រើសរើស និងដកស្រង់ចេញពីប្រភពល្អៗ ដូចជាការបកស្រាយរបស់នីតិករ អ្នកមានបទពិសោធន៍នៅក្នុងវិស័យនេះផ្ទាល់ មតិយោបល់ពីអ្នកជំនាញការខាងច្បាប់ព្រហ្មទណ្ឌ ច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា និងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

ចំពោះរចនាសម្ព័ន្ធនៃកាស្រាវជ្រាវលើការសរសេរសារណានេះ ត្រូវបានធ្វើការបែងចែកជា៣ ជំពូកធំៗគឺរួមមាន៖

**ជំពូកទី១ លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

**ជំពូកទី២ លំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន**

**ជំពូកទី៣ ការអនុវត្តទោសចំពោះអនីតិជន**

# ជំពូកទី១

# លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

# ជំពូកទី១

# លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ បណ្តឹងដែលអាចកើតឡើងមានពីរ ដែលត្រូវបានកំណត់យ៉ាងជាក់លាក់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងទាំងពីរនោះរួមមាន៖

- **បណ្តឹងអាជ្ញា** មានគោលបំណងពិនិត្យពីអត្ថិភាពនៃបទល្មើស បង្ហាញពីពិរុទ្ធភាពនៃបទល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។
- **បណ្តឹងរដ្ឋប្បវេណី** មានគោលបំណងធ្វើឲ្យ បានជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។[1]

នៅក្នុងការស្រាវជ្រាវលើការសរសេរសារណានេះ យើងខ្ញុំលើកយកពាក់ព័ន្ធតែនឹងបណ្តឹងអាជ្ញាមកធ្វើការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។ ជាគោលការណ៍ទូទៅ នៅក្នុងក្រមព្រហ្មទណ្ឌនៅពេលដែលមានបទល្មើសមួយកើតឡើង ទោះអំពើនោះប្រព្រឹត្តឡើងដោយចេតនាក្តី ឬ អចេតនាក្តី ដែលជាហេតុបណ្តាលឲ្យមានព្យសនកម្មដល់បុគ្គលដទៃ គឺជាលក្ខខណ្ឌចម្បងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ (ផ្នែកទី១) បានផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ (ផ្នែកទី២)។

## ផ្នែកទី១៖ លក្ខខណ្ឌអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ។[2] ការលំបាកក្នុងការកំណត់អាយុពិតរបស់អនីតិជននៅត្រង់ថា មិនទាន់មានវិធីសាស្ត្របញ្ជាក់ពីអាយុតាមលក្ខណៈវិទ្យាសាស្ត្រ ឬ វេជ្ជសាស្ត្រឲ្យបានត្រឹមត្រូវនៅឡើយ។ ជាដំណោះស្រាយដ៏ល្អ និងយូរអង្វែង គួរកំណត់លក្ខខណ្ឌផ្លូវច្បាប់ដល់ឪពុកម្តាយឲ្យចុះសំបុត្រកំណើតដល់កូន បើពុំមានទេត្រូវផាកពិន័យ ក្នុងករណីបរាជ័យលើការចុះ

[1] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[2] មាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សំបុត្រកំណើតដល់កូន។ ដើម្បីអនុវត្តគោលការណ៍ចំពោះអនីតិជនឲ្យខុសពីមនុស្សពេញវ័យ វាពិតជាសំខាន់ណាស់ក្នុងការកំណត់អាយុរបស់ពួកគេ ថាតើអនិតិជនពិតជាមានអាយុ ១៤ (ដប់បួន) ឆ្នាំ ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬក៏ពួកគេមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ឬក៏លើស ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលគេបានប្រព្រឹត្តបទល្មើស។ ការកំណត់អាយុនៅក្នុងដំណើររឿងក្ដីព្រហ្មទណ្ឌ គឺជាប្រយោជន៍មួយក្នុងចំណោមប្រយោជន៍ជាច្រើនដែលចាំបាច់ត្រូវតែមាន។ ជាមួយគ្នានេះដែរ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌអាយុខាងលើ យើងខ្ញុំធ្វើការបែងចែកអនីតិជនជាពីរប្រភេទគឺៈ

**១.អនីតិជនមានអាយុក្រោម ១៤ ឆ្នាំ**

អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលដែលប្រព្រឹត្តបទល្មើសគឺច្បាប់បានកំណត់ថា មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយហេតុថា ទាញចេញពីអនុសញ្ញាស្ដីពីសិទ្ធិកុមារត្រង់មាត្រា ៤០ ចំណុចទី៣ កថាខណ្ឌ"ក" បានតម្រូវឲ្យរដ្ឋភាគី ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវធ្វើការកំណត់កំរិតអាយុអប្បបរមា នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលមានអាយុក្រោមអប្បបរមារនេះ កុមារត្រូវបានសន្មតជាមុនថាពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ។[3] រីឯមាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជនត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ បានចែងថា អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់ជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។[4] ចំណែកឯមាត្រា ២៧ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន កថាខណ្ឌទី១ ក៏បានចែងផងដែរថា "ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម"។

តាមខ្លឹមសារខាងលើនេះ អាចនាំឲ្យគេសន្មតបានថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បបរមា នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬ អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ពុំទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍ៈ ក្មេងប្រុសអាយុ ១០ (ដប់) ឆ្នាំ ម្នាក់បានយកដំបងទៅវៃក្បាលក្មេងប្រុសម្នាក់ទៀតដែរឈរក្បែរនោះ បណ្ដាលឲ្យបែកក្បាលរងរបួសជាដំណំ។ ក្នុងករណីនេះ ក្មេងដែលបានប្រព្រឹត្តបទល្មើសនោះ មិនអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ អាស្រ័យដោយហេតុថាក្មេងនោះនៅមិនទាន់មានការយល់ដឹងខុសត្រូវពីអំពើរបស់ខ្លួននៅឡើយ។

គួរកត់សម្គាល់ដែរថា អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ សច្ចាធារណ៍មិនអាចប្រកែកបាននៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលរារាំងចំពោះការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្ដីសម្រេចនោះទេ (ការស្ដីបន្ទោស ឬ វិធានការអប់រំ)។

[3] មាត្រា ៤០ ចំណុចទី៣ កថាខណ្ឌ"ក" នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ

[4] មាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ដូច្នេះ តុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះឲ្យចូលខ្លួនមកកាន់តុលាការបានផងដែរ ក្នុងគោលបំណងដើម្បីប្រកាសសេចក្ដីសម្រេចដាក់ឲ្យអនុវត្តវិធានការណាមួយ ដែលតុលាការបានធ្វើការសម្រេចលើអនីតិជននោះ។ វិធានការទាំងនោះរួមមាន៖ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ឬ ក៏ប្រគល់អនីតិជននោះទៅឲ្យសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬ ស្ថាប័នឯកទេស និងអាចដាក់អនីតិជននោះឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការបានផងដែរ។

### ២.អនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ វិញ នៅពេលដែលអនីតិជនប្រភេទនេះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ហេតុដែលច្បាប់តម្រូវឲ្យមានការទទួលខុសត្រូវ ព្រោះយល់ឃើញថា អនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ។ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ ការយល់ឃើញយ៉ាងដូច្នេះ នីតិករបានពិចារណាដោយផ្អែកទៅលើ ការរីកចម្រើនអំពីរូបរាងកាយ ប្រាជ្ញា ស្មារតី និងការសន្សំនូវបទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅរបស់អនីតិជននោះឯង។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យច្បាប់សន្មតបានថា អនីតិជនប្រភេទនេះអាចពិចារណាយល់ដឹងបានគ្រប់គ្រាន់នូវរាល់ការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចបញ្ជាបាននូវរាល់អំពើរបស់ខ្លួនថែមទៀតផង។ ថ្វីត្បិតតែច្បាប់បានតម្រូវឲ្យ អនីតិជនប្រភេទនេះមានការទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានប្រព្រឹត្តក៏ពិតមែន ប៉ុន្តែការទទួលខុសត្រូវនេះមិនមានលក្ខណៈពេញលេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននេះត្រូវទទួលរងគឺ មានកម្រិតស្រាលជាងនីតិជន។ ហើយដើម្បីអាចសម្រេចផ្តន្ទាទោសលើអនីតិជនបាន តុលាការត្រូវពិចារណា ថ្លឹងថ្លែងជាមុនសិនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជននេះបានប្រព្រឹត្ត និងរួមទាំងបុគ្គលិកលក្ខណៈរបស់អនីតិជនប្រភេទនេះផងដែរ។ ចំពោះទោសដែលត្រូវទទួលរងវិញគឺ អាចមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ឬអាចហៅបានម៉្យាងទៀតថា មូលទោស។

សូមបញ្ជាក់ថា បើទោះបីជាអនីតិជនអាចទទួលរងនូវទោសបែបនេះក៏ដោយ ក៏កម្រិតនៃទោសដែលទទួលរងគឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាល បើប្រៀបធៀបទៅនឹងទោសដែលមានចែងចំពោះនីតិជន។ ជារួម គេអាចយល់បានថាការបន្ថយទោសចំពោះអនីតិជនអាចបណ្ដាលមកពីមូលហេតុ **អនីតិភាពនៃទណ្ឌិត** នេះឯង។

ឧទាហរណ៍៖ ក្មេងស្រី ក មានអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ បានឈ្លោះប្រកែកជាមួយក្មេងប្រុស ខ។ នៅពេលឈ្លោះប្រកែកនោះក្មេងស្រី ក បានជ្រុលដៃចាក់ក្មេងប្រុស ខ មួយកាំបិតចំកញ្ចឹងកបណ្ដាលឲ្យស្លាប់។ អំពើដែលក្មេងស្រី ក បានប្រព្រឹត្តមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ដូច្នេះ ចំពោះទោសដែលត្រូវអនុវត្តចំពោះក្មេងស្រីនោះគឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាល បើធៀបទៅនឹងទោសដែលត្រូវអនុវត្តចំពោះនីតិជន។

ដោយហេតុថា អនីតិជនមិនទាន់ចាត់ទុកថាមានភាពចាស់ទុំ ឬមានការទទួលខុសត្រូវគ្រប់គ្រាន់ និងវិនិច្ឆ័យលើអំពើរបស់ខ្លួនដូចជាមនុស្សពេញវ័យនោះទេ។

## ផ្នែកទី២៖ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន

យោងតាមគោលការណ៍នៃការកំណត់ទណ្ឌកម្ម ឬ គោលការណ៍ក្នុងការកំណត់ការផ្តន្ទាទោស ចៅក្រមដើម្បីអាចផ្តន្ទាទោសជនល្មើសម្នាក់បាន ត្រូវពិចារណាអំពីបាតុភូតសង្គមដែលជាបទល្មើសបានកើតឡើងឲ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន ទើបធ្វើការសម្រេចផ្តន្ទាទោសទៅលើចារីនោះបាន។ មានន័យថា ដើម្បីអាចចេញនូវសេចក្តីសម្រេចប្រកបដោយសុក្រិត្យភាព និងសុភវិនិច្ឆ័យ ចៅក្រមត្រូវពិចារណាទៅលើបីចំណុចសំខាន់ៗគឺ៖

១.ត្រូវពិចារណាពាក់ព័ន្ធនឹងបញ្ហាដែលមានចែងនៅក្នុងច្បាប់ ពោលគឺសំដៅទៅដល់គោលការណ៍នីត្យានុកូលនៃទោស។

២.គឺត្រូវពិចារណាទៅលើស្ថានភាពនៃការប្រព្រឹត្តបទល្មើសថា តើបទល្មើសនោះបានប្រព្រឹត្តនៅក្នុងកាលៈទេសៈណា? ពេលវេលាណា? ទីកន្លែងណា?

៣.គឺត្រូវពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះផងដែរ។

តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដោយផ្តោតលើកាលៈទេសៈនៃបទល្មើស(១) ឬបុគ្គលិកលក្ខណៈរបស់អនីតិជន(២)។

### ១.កាលៈទេសៈនៃបទល្មើស

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៨ បានកំណត់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌបានលុះត្រាតែមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ដោយហេតុថាអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺជាអនីតិជនដូចនេះការយល់ដឹងរបស់ពួកគេនៅមានភាពខ្វះខាតនៅឡើយ។ តែប្រសិនបើ អនីតិជនបានប្រព្រឹត្តបទល្មើសអ្វីមួយនោះ វិធានការអនុវត្តចំពោះអនីតិជនគឺមានតែ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ តែប៉ុណ្ណោះ។ ប៉ុន្តែចំណុចនេះអាចមានការពិបាក ដោយហេតុថា ក្នុងករណីដែលមានអនីតិជនអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទល្មើសដែលមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរណាមួយ។ ប៉ុន្តែនៅក្នុងមាត្រា ៣៩ កថាខណ្ឌទី ២ បានបញ្ញត្តិបន្ថែមថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ មានន័យថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ឲ្យបានច្បាស់លាស់នូវឡើយអំពីពាក្យថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដូចនេះនៅពេលជួបប្រទះករណីណាមួយ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការដែលគេហៅម៉្យាងទៀតថា ឆន្ទានុសិទ្ធិក្នុងការគិតពិចារណាថា តើអនីតិជននោះត្រូវទទួលខុសត្រូវ ឬក៏អត់ចំពោះទង្វើល្មើសច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។

**២.បុគ្គលិកលក្ខណៈរបស់អនីតិជន**

ជាទូទៅរាល់អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសទាំងអស់ តុលាការអាចសម្រេចដាក់ត្រឹមតែវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ ដែលមានដូចជា៖

១.ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងទំនុកចិត្ត។

២.ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣.ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទានៅក្នុងការទទួលអនីតិជន។

៤.ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។

៥.ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ត្រង់ចំណុចនេះ មានន័យថា តុលាការត្រូវចាត់តាំងបុគ្គលណាមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះត្រូវធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀតទាត់ដល់ព្រះរាជអាជ្ញា។ ការកំណត់បុគ្គលិកលក្ខណៈរបស់ជនល្មើស យើងអាចកំណត់បានតាមរយៈរបបវេជ្ជសាស្ត្រ និងរបបតាមបែបធម្មជាតិ។ ក៏ប៉ុន្តែ ចំពោះអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលមានស្ថានទម្ងន់ធ្ងន់ធ្ងរ តុលាការអាចសម្រេចផ្តន្ទាទោសអនីតិជនដោយបន្ថយពាក់កណ្តាលនៃទោសដែលអនុវត្តចំពោះនីតិជន។

# ជំពូកទី២

# លំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន

# ជំពូកទី២

# លំហូរនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន

នៅពេលដែលអនីតិជនត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នីតិវិធីដែលត្រូវយកមកអនុវត្តលើអនីតិជននោះត្រូវបានធ្វើឡើងទៅតាមដំណាក់កាលដែលច្បាប់បានកំណត់។ នៅគ្រប់ដំណាក់កាលទាំងអស់ ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ជាទីបំផុត ដោយភ្នាក់ងារសមត្ថកិច្ច និងត្រូវគិតគូរដល់ឧត្តមប្រយោជន៍របស់អនីតិជនជាមុន។

ជាគោលការណ៍ ដើម្បីធ្វើការសិក្សាឲ្យមានភាពច្បាស់លាស់ និងស៊ីជម្រៅនោះ យើងគម្បីសង្កេតទៅលើឬសគល់សំខាន់ៗ ដែលនឹងធ្វើឲ្យយើងស្វែងយល់អំពីដំណើការនៃនីតិវិធី តាមលំដាប់លំដោយដូចខាងក្រោម៖

- **ដំណាក់កាលនៃការស៊ើបអង្កេត** ដែលយើងអាចនិយាយបានថាជាដំណាក់កាល នៃនគរបាលយុត្តិធម៌ និងដំណាក់កាលព្រះរាជអាជ្ញា។
- **ដំណាក់កាលនៃការចោទប្រកាន់** គឺជាដំណាក់កាលនៃបណ្ដឹងអាជ្ញា ឬ ការដាក់បណ្ដឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ (ដំណាក់កាលនេះជាដំណាក់កាលព្រះរាជអាជ្ញា)។
- **ដំណាក់កាលនៃការស៊ើបសួរ** គឺជាដំណាក់កាលស្វែងរកការពិត (ស្វែងរកភស្តុតា) ជាដំណាក់កាលមួយដែលចៅក្រមស៊ើបសួរត្រូវតែស្វែងរកការខុសត្រូវ។
- **ដំណាក់កាលជំនុំជម្រះ** ជាដំណាក់កាលមួយដែលស្ថិតនៅក្នុងយុត្តាធិការជំនុំជម្រះ និងដើម្បីឈានទៅធ្វើការអនុវត្តទោស ឬក៏ធ្វើការដោះលែងឲ្យមានសេរីភាព។
- **ដំណាក់កាលនៃការអនុវត្តទោស** មិនជាទូទៅទេព្រោះរឿងក្ដីទាំងអស់មិនសុទ្ធសឹងតែអនុវត្តទោសទាំងអស់នោះទេ ដោយរឿងក្ដីខ្លះក៏ត្រូវដោះលែងការចោទប្រកាន់ដែរ។

នៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ ក៏បានចែងអំពីលំហូរនីតិវិធីតាមលំដាប់ដែលត្រូវយកមកអនុវត្តចំពោះអនីតិជន មុនពេលឈានដល់ការសម្រេចដាក់ទោសលើអនីតិជនផងដែរ។ នៅដំណាក់កាលនីមួយៗមានដូចជា៖ ដំណាក់កាលនគរបាលយុត្តិធម៌ (ផ្នែកទី១), ដំណាក់កាលអយ្យការ (ផ្នែកទី២), ដំណាក់កាលចៅក្រមស៊ើបសួរ (ផ្នែកទី៣), និងដំណាក់កាលសវនាការរបស់ចៅក្រមជំនុំជម្រះ (ផ្នែកទី៤)។

## ផ្នែកទី១៖ ដំណាក់កាលនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង។ បន្ទាប់ពីនគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្ដីពីការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គការដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន។ ដោយឡែកសមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានវិសាលភាពត្រឹមតែលើព្រំប្រទល់ដែនដីនៃអង្គភាពដែលត្រូវបានចាត់

តាំងតែប៉ុណ្ណោះ។ ហើយគ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមាន ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់កំណត់ជាបន្ទាន់។ ប៉ុន្តែ ក្នុងករណីដែលអនីតិជននោះបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការសម្រុះសម្រួល រវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទបានទេ។

### ១.អំពីការចាប់ខ្លួនអនីតិជនដែលប្រព្រឹត្តបទល្មើស

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។[5] ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ វិញ នគរបាលយុត្តិធម៌អាចចាប់ខ្លួនបានតែក្នុងករណីដែលអនីតិជននោះបានប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ដោយឡែកអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជននោះបានតែក្នុងករណីដែលអនីតិជននោះបានប្រព្រឹត្តបទមជ្ឈិមដោយចេតនា តែប៉ុណ្ណោះ។ បន្ទាប់ពីធ្វើការចាប់ខ្លួនអនីតិជន នគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

ចំពោះការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គការដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត។[6]

ទោះបីជាយ៉ាងណាក៏ដោយ ការចាប់ខ្លួន និងការឃាត់ខ្លួនអនីតិជន គួរអនុវត្តសម្រាប់តែវិធានការចុងក្រោយបំផុតប៉ុណ្ណោះ។ ការចាប់ខ្លួនត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់ ទោះជាការចាប់ខ្លួននោះ ត្រូវធ្វើឡើងតាមដីកាចាប់ខ្លួនតាមភស្តុតាងស៊ីសង្វាក់ ឬតាមបទល្មើសជាក់ស្តែងក្តី។[7]

### ២.ការឆែកឆេរ

ចំពោះការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើឡើងដោយ បុគ្គលដែលមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និតជាមួយអនីតិជននោះ លើកលែងតែក្នុងករណីមិនអាចចៀសបាន។ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជន នោះមន្ត្រីត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ។

---

[5] មាត្រា ១៤ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[6] មាត្រា ១៥ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[7] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា ៩ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

### ៣.ការឃាត់ខ្លួនអនីតិជនដែលប្រព្រឹត្តបទល្មើស

ការឃាត់ខ្លួនធ្វើឡើងដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស។[8] ការឃាត់ខ្លួន អនុញ្ញាតឲ្យនគរបាលយុត្តិធម៌រក្សាទុកជននោះឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់ខ្លួនសម្រាប់ការស៊ើបអង្កេត និងស្តាប់ចម្លើយ។[9] បើផ្អែកតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ១៧ បានចែងថា មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បាន ប្រសិនបើ មន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ។ ប៉ុន្តែ អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។ ការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ។

រយៈពេលនៃការឃាត់ខ្លួនអនីតិជនមិនអាចពន្យារពេលឡើយ ហើយការឃាត់ខ្លួននេះត្រូវតែអនុវត្តយ៉ាងជាក់លាក់តាមការកំណត់[10]៖

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ (សាមសិបប្រាំមួយ) ម៉ោងឡើយ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ (ម្ភៃបួន) ម៉ោងឡើយ។
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោងឡើយ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ (សាមសិបប្រាំមួយ) ម៉ោងឡើយ។
- អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតដែលអាចធ្វើទៅបាន។[11]

[8] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[9] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទេសសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ស្តីពីនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី ឆ្នាំ២០១៧

[10] មាត្រា ៩៦ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[11] មាត្រា១៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## តារាងថិរវេលានៃការឃាត់ខ្លួន

| បទល្មើស និងមាត្រា | អាយុជនសង្ស័យ | ថិរវេលាអតិបរមាដំបូង នៃការឃាត់ខ្លួន | ការពន្យាថិរវេលានៃការឃាត់ខ្លួន |
|---|---|---|---|
| បទឧក្រិដ្ឋ ម.៩៦ កថាខណ្ឌទី២,ទី៣ | ចាប់ពី ១៨ឆ្នាំ ឬ ចាស់ជាងនេះ | អាចឃាត់ខ្លួន ៤៨ ម៉ោង | ២៤ម៉ោង<br>មិនគិតពីថិរវេលាចាំបាច់ក្នុងការដឹងជញ្ជូន |
| បទមជ្ឈិម ម.៩៦ កថាខណ្ឌទី២ | ចាប់ពី ១៨ឆ្នាំ ឬ ចាស់ជាងនេះ | អាចឃាត់ខ្លួន ៤៨ ម៉ោង | មិនអាចពន្យារការឃាត់ខ្លួនបានឡើយ |
| បទឧក្រិដ្ឋ ម.៩៦ កថាខណ្ឌទី៧ | ចាប់ពី ១៦ឆ្នាំ-ក្រោម ១៨ឆ្នាំ | មិនឲ្យហួសពី ៤៨ ម៉ោង | មិនអាចពន្យារការឃាត់ខ្លួនបានឡើយ |
| បទឧក្រិដ្ឋ ម.៩៦ កថាខណ្ឌទី៥ | ចាប់ពី ១៤ឆ្នាំ-ក្រោម ១៦ឆ្នាំ | មិនឲ្យហួសពី ៣៦ ម៉ោង | មិនអាចពន្យារការឃាត់ខ្លួនបានឡើយ |
| បទមជ្ឈិម ម.៩៦ កថាខណ្ឌទី៨ | ចាប់ពី ១៦ឆ្នាំ-ក្រោម ១៨ឆ្នាំ | មិនឲ្យហួសពី ៣៦ ម៉ោង | មិនអាចពន្យារការឃាត់ខ្លួនបានឡើយ |
| បទមជ្ឈិម ម.៩៦ កថាខណ្ឌទី៦ | ចាប់ពី ១៤ឆ្នា-ក្រោម ១៦ឆ្នាំ | មិនឲ្យហួសពី ២៤ ម៉ោង | មិនអាចពន្យារការឃាត់ខ្លួនបានឡើយ |
| ម.៩៦ កថាខណ្ឌទី៩ | ក្រោម ១៤ឆ្នាំ | មិនអាចត្រូវឲ្យឃាត់ខ្លួនឡើយ | |

### ៤.ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

បន្ទាប់ពីអនីតិជន ត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាលយុត្តិធម៌ មន្ត្រីទទួលបន្ទុកត្រូវជូនដំណឹងពីការបានចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជនទៅដល់បុគ្គលដែលមានកាតព្វកិច្ចពាក់ព័ន្ធជាមួយនឹងអនីតិជនជាបន្ទាន់ ឬក្នុងពេលខ្លីបំផុត។ បុគ្គលដែលនគរបាលយុត្តិធម៌ត្រូវជូនដំណឹងអំពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជនទាំងនោះមានដូចជា៖

- អ្នកតំណាងរបស់អនីតិជនដែលច្បាប់បានកំណត់ ហើយក្នុងករណីមិនអាចទាក់ទងបាន នោះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រឹងប្រែងទាក់ទងនឹងអ្នកទំនុកបម្រុងផ្សេងទៀតដែលអនីតិជន ឬនគរបាលយុត្តិធម៌ជាអ្នកជ្រើសរើស ដោយមានការយល់ព្រមពីអនីតិជននោះ
- ភ្នាក់ងារសង្គមកិច្ច ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ
- មេធាវីរបស់អនីតិជន ដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ឬអាចជ្រើសតាំងមេធាវីឲ្យអនីតិជន ប្រសិនបើអនីតិជននោះគ្មានមេធាវី
- អ្នកបកប្រែភាសា ដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជនមិនមែនជាជនជាតិខ្មែរ ឬមិនចេះភាសាខ្មែរ។

ការជូនដំណឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជាក់អំពីមូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន ប្រភេទនៃបទល្មើស ទីកន្លែងដែលអនិតិជនកំពុងស្ថិតនៅ និងសិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាព

នគរបាល។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច។[12]

### ៥.នីតិវិធីនៃការស្តាប់ចម្លើយ

មុនពេលចាប់ផ្តើមនីតិវិធីស្តាប់ចម្លើយ អនីតិជនទទួលបានសិទ្ធិសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជន និងជាសម្ងាត់ ប្រសិនបើមានការស្នើសុំ។

ពេលនីតិវិធីស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តតាមមាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានបញ្ញត្តិដូចតទៅៈ

- មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានរបស់អនីតិជន ដែលមានចែងនៅក្នុងច្បាប់
- ការស្តាប់ចម្លើយ ត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី មានលក្ខណៈជាឯកជន និងជាសម្ងាត់
- អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចដែលមានសិទ្ធិ ហើយអាចផ្តល់ជំនួយដល់អនីតិជន មានសិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយ
- មន្ត្រីនគរបាលយុត្តិធម៌ អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយ ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- ក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬមេធាវីរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ចក្នុងពេលស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាននោះ ហើយបញ្ចូលក្នុងសំណុំរឿងរបស់អនីតិជន
- បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន
- មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ
- អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ ដោយត្រូវចុះនិទ្ទេស
- អ្នកតំណាងដែលច្បាប់កំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុនោះ

[12] មាត្រា ១៨ កថាខណ្ឌទី៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

### ៦.កំណត់ហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

រាល់ការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះបញ្ជីស្តីពីការចាប់ខ្លួន និងឃាត់ខ្លួនអនីតិជន និងកំណត់ហេតុសរុបនៃការចាប់ខ្លួន និងឃាត់ខ្លួន។ នៅក្នុងករណីដែលមេធាវីរបស់អនីតិជននោះ បានធ្វើការស្នើសុំឲ្យមន្ត្រីនគរបាលយុត្តិធម៌ ត្រូវផ្តល់ច្បាប់ចម្លងនៃកំណត់ហេតុសរុបនៃការចាប់ខ្លួន ឬឃាត់ខ្លួន អនីតិជនឲ្យមេធាវីតាមការស្នើសុំ។

នៅតាមអង្គភាពដែលមាននគរបាលយុត្តិធម៌នីមួយៗ ត្រូវមានបញ្ជីដោយឡែកស្តីពីឃាត់ខ្លួនអនីតិជន។ ចំណុចសំខាន់ៗ ដែលត្រូវចុះក្នុងបញ្ជីឃាត់ខ្លួនរួមមាន៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោង ដែលចាប់ផ្តើមធ្វើការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាឲ្យឃាត់ខ្លួន
- ឈ្មោះរបស់គ្រូពេទ្យ ដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការ ពេលផុតកំណត់ការឃាត់ខ្លួន
- បញ្ជីនេះ ត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ។[13]

មន្ត្រីនគរបាលយុត្តិធម៌គ្មានសិទ្ធិក្នុងការធ្វើនីតិវិធីបង្វែររឿងក្តីដែលពាក់ព័ន្ធនឹងអនីតិជនឡើយ។

## ផ្នែកទី២៖ ដំណាក់កាលអង្គការអយ្យការ

គ្រប់នីតិវិធីនៅក្នុងដំណាក់អយ្យការ ព្រះរាជអាជ្ញាត្រូវតែធ្វើការផ្ទៀតផ្ទាត់អាយុរបស់អនីតិជន។ នៅពេលដែលទទួលបានសំណុំរឿងពីនគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ប៉ុន្តែគ្មានជនជាប់សង្ស័យមកជាមួយនោះ ព្រះរាជអាជ្ញា គម្បីឲ្យដំណឹងដល់ឪពុកម្តាយ អាណាព្យាបាល របស់អនីតិជនដែលជាប់សង្ស័យអំពី បទចោទប្រកាន់ផ្សេងៗ ក្រោយពីចុះបញ្ជីសំណុំរឿងក្តីរួច។ ចំពោះការចោទប្រកាន់ គឺជាតួនាទីចាំបាច់របស់ស្ថាប័នអយ្យការ។ ការចោទប្រកាន់ធ្វើឡើងតាមរយៈបណ្តឹងអាជ្ញា។ ដោយអនុលោមតាមមាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ បានកំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។[14] ចៅក្រមអយ្យការ និងចៅក្រមដែលត្រូវបានចាត់ឲ្យទទួលបន្ទុកលើរឿងក្តីអនីតិជន ទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវទទួលបន្ទុក

[13] មាត្រា ១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[14] មាត្រា ៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

លើរឿងក្តីអនីតិជនរហូតដល់មានចៅក្រមជំនាញទាក់ទងនឹងអនីតិជនមកទទួលបន្ត។ ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្តីអនីតិជន ទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាត ឬមិនដាច់ខាតក្តី។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យការរឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន។[15]

### ១.សមត្ថកិច្ចរបស់អង្គការអយ្យការ និងការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

នៅពេលដែលព្រះរាជអាជ្ញាទទួលបានកំណត់ហេតុ ឬរបាយការណ៍របស់អនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវពិនិត្យសំណុំឯកសារ និងពាក្យប្តឹងដែលខ្លួនបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុរបស់អនីតិជន។

នៅដំណាក់កាលអយ្យការ ការពិនិត្យអំពីអាយុរបស់អនីតិជន គឺជាចំណុចដំបូងដើម្បីបញ្ជាក់ថាជនសង្ស័យពិតជាមានអាយុគ្រប់ ឬលើសពី ១៤ (ដប់បួន) ឆ្នាំ ដើម្បីអាចឲ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះ ដើម្បីបញ្ជាក់ពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាអាចពិនិត្យមើលលើឯកសារផ្លូវការដែលអាចជឿទុកចិត្តបាន ដែលមានដូចជា សំបុត្រកំណើតរបស់អនីតិជន សៀវភៅស្នាក់នៅ ប័ណ្ណគ្រួសារ ឬការពិនិត្យលើកោសល្យវិច័យរបស់អ្នកបច្ចេកទេស។ល។ ក្នុងករណីដែលមានការសង្ស័យលើ ឬមិនអាចបញ្ជាក់បានពីអាយុពិតរបស់អនីតិជនជាប់សង្ស័យនោះទេ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីធ្វើការស្វែងរកឲ្យឃើញពីអាយុពិតប្រាកដរបស់អនីតិជននោះ។[16] ក៏ប៉ុន្តែ បើការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋានអំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ។ ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតត្រឹមថ្ងៃដែលគេត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជននោះ ទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ។[17]

### ២.នីតិវិធីនៃការស្តាប់ចម្លើយ

បន្ទាប់ពីសន្និដ្ឋានពីអាយុពិតប្រាកដរបស់អនីតិជន (ស្មើ ឬលើស ១៤ ឆ្នាំ) ហើយ ព្រះរាជអាជ្ញាអាចធ្វើការស្តាប់ចម្លើយបាន។ មុនពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយ អំពីសិទ្ធិដែលមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង

[15] មាត្រា ២៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[16] គោលការណ៍ណែនាំស្តីពី យុត្តិធម៌អនីតិជន របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៥, មាត្រា ៤០ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩

[17] មាត្រា ២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្ដី ប្រសិនបើការចូលរួមនេះ មិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។

ការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីបែបកុមារមេត្រី។[18]

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាមអនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន។ ក្នុងករណី អនីតិជន មិនអាចអានបានមន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់។

អនីតិជនអាចសុំកែប្រែ ឬ បន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ ដោយត្រូវចុះនិទ្ទេស។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។ ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

**៣.ការបង្វែរ**

ការបង្វែគឺជាវិធានការដែលអាចប្រើប្រាស់ក្នុងករណីដែលអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗនៃនីតិវិធីតុលាការ។[19]

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

[18] មាត្រា ២៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[19] មាត្រា ៦០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- លើកទឹកចិត្តអនិតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ សហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធន៍អាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសារជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសនៅក្នុងបញ្ជីថ្កោលទោស។[20]

### ៣.១ លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ការប្រើប្រាស់នីតិវិធីបង្វែរត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម៖

ក.មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន។

ខ.អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ។

គ.បទល្មើសដែលបានប្រព្រឹត្ត ជាបទលហុ ឬ បទមជ្ឈិម។

ឃ.អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ។[21]

### ៣.២ លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ

ក្នុងរឿងក្តីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម៖

ក.កាលៈទេសៈនៃបទល្មើស។

ខ.ស្ថានភាពនៃបទល្មើស។

គ.បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត។

ឃ.ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន។

ង.ព្យសនកម្មរបស់ជនរងគ្រោះ។

[20] មាត្រា ៦២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[21] មាត្រា ៦៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ច.សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម។[22]

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាននៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ការសង្គមកិច្ច។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត។[23]

**៣.៣ នីតិវិធីនៃការបង្វែរ**

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងមាត្រា ៦៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចការបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន។

**ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម៖**

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតា វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន។

**ផែនការបង្វែរសម្រាប់អនីតិជនត្រូវ៖**

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត
- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន

[22] មាត្រា ៦៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[23] មាត្រា ៦៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង

- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។[24]

**៣.៤ ការទទួលបន្ទុកក្នុងការបង្វែរ**

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានារ៉ាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ។

## ផ្នែកទី៣៖ ដំណាក់កាលចៅក្រមស៊ើបសួរ

ក្រោយពេលដែលបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម។

- ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមសើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។[25] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ បានកំណត់អំពីតួនាទីរបស់ចៅក្រមស៊ើបសួរ (៣.១) និងអំណាចរបស់ចៅក្រមស៊ើបសួរ (៣.២) មានដូចខាងក្រោម៖

**១.តួនាទីរបស់ចៅក្រមស៊ើបសួរ**

ដោយផ្អែកទៅលើប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើសួរ មានតួនាទីយ៉ាងសំខាន់ដើម្បីស្វែងរកការពិត។ ដោយសារតួនាទីដ៏សំខាន់របស់ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ដែលជាសេចក្តីសម្រេចដែលមានការប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គល។

**១.១ សមត្ថកិច្ចនៃការស៊ើបសួរ**

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើងដែលពាក់ព័ន្ធនឹងអនីតិជន ការស៊ើបសួរករណីទាំងឡាយ ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន។ អនុឡោមតាមមាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិអំពីសមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរគឺ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស

- ចៅក្រមស៊ើបសួរនាលំនៅដ្ឋាន ឬទីសំណាក់របស់បុគ្គលដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស

- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស។

**១.២ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ**

ចៅក្រមស៊ើបសួរអាចដាក់អនីតិជន ដែលជាជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជនដែលជាជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់

---

[24] មាត្រា ៦៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[25] មាត្រា ៣២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ៖

- ឲ្យស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ឲ្យស្ថិតក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប។

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ។

វិធានដែលបានប្បញ្ញត្តិនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

### ១.៣ នីតិវិធីនៃការស្តាប់ចម្លើយ

ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់ជានីតិវិធីកុមារមេត្រី។[26] ការស្តាប់ចម្លើយត្រូវមានវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច។

ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន។ ក្នុងករណី អនីតិជនមិនអាចអានបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ។

---

[26] មាត្រា ៣៥ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានការស្នើសុំ។ ករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ។

វិធានដែលបានប្បញ្ញត្តិនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

### ២.អំណាចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។ ប៉ុន្តែ ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។

### ៣.អំណាចក្នុងការបង្វែរ

ការបង្វែរ គឺជាការផ្ទេររឿងក្តីកម្រិតស្រាល ឬមិនធ្ងន់ធ្ងរ (បទលហុ, បទមជ្ឈិម) ចេញពីនីតិវិធីព្រហ្មទណ្ឌ ហើយបញ្ជូនអនីតិជនដែលបានប្រព្រឹត្តបទល្មើសទៅរកជំនួយគាំទ្រពីសហគមន៍ ក្នុងករណីដែលអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស។

មាត្រា ៦០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវយកមកអនុវត្ត ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីជាផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ។

### ៤.ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការមួយដែលដកហូតនូវសេរីភាពរបស់ជនត្រូវចោទដោយការសម្រេចសេចក្តីរបស់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ។ គោលបំណងនៃការឃុំខ្លួនបណ្តោះអាសន្ន គឺដើម្បីធានានូវដំណើរការឲ្យមានប្រសិទ្ធិភាពខ្ពស់ក្នុងការស្វែងរកការពិតដោយចៅក្រមស៊ើបសួរធ្វើការបញ្ជូនសំណុំរឿងទៅធ្វើការជំនុំជម្រះ។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ឡើងទៅ។[27] បន្ថែមលើបញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួន

[27] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បណ្ដោះអាសន្នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ។ នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ «ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន» ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់ដោយឡែកពីគ្នាទៅតាមស្ថានភាពនៃជនត្រូវចោទ (នីតិជន ឬ អនីតិជន) ឬលក្ខណៈនៃបទល្មើស (បទមជ្ឈិម ឬបទឧក្រិដ្ឋ)។

**ជនត្រូវចោទជាអនីតិជន ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវកំណត់ដូចខាងក្រោម៖**

**ក. ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំនឹងត្រូវចោទប្រកាន់ ពីបទឧក្រិដ្ឋ ដែលថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ៖**

- ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ)ឆ្នាំ។
- ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**ខ. បើក្នុងករណីជាបទមជ្ឈិមវិញ ការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ត្រូវបានកំណត់ដូចខាងក្រោម៖**

- ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។
- ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ វិញមិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ។

ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឲ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ (មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ) និងមាត្រា ៣៩ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បានចែងថា អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ ។

**តារាងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

| បទល្មើស និងមាត្រា | អាយុជនជាប់ចោទ | ថិរវេលាអតិបរមាដំបូង នៃការឃុំខ្លួន | ការពន្យាថិរវេលានៃការឃុំខ្លួនតាមរយៈដីកាឃុំខ្លួនមួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ ម.២០៨ | ចាប់ពី ១៨ឆ្នាំ ឬចាស់ជាងនេះ | មិនអាចលើសពី ៦ ខែ | ៦ ខែ + ៦ ខែ |
| បទមជ្ឈិម ម.២០៩ | ចាប់ពី១៨ឆ្នាំ ឬចាស់ជាងនេះ | មិនអាចលើសពី ៤ ខែ | - ២ ខែ<br>- មិនត្រូវលើសពីពាក់កណ្តាលអប្បរមានៃទោសដែលច្បាប់បានកំណត់ |
| បទឧក្រិដ្ឋ ម.២១៣ | ចាប់ពី១៦-ក្រោម១៨ឆ្នាំ | មិនលើសពី ៦ខែ | មិនអាចពន្យាពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ ម.២១៣ | តិចជាង១៦ឆ្នាំ | មិនលើសពី ៤ខែ | មិនអាចពន្យាពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម ម.២១៤ | ចាប់ពី១៦-ក្រោម១៨ឆ្នាំ | - មិនលើសពី ៤ខែ<br>- មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបមារនៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។ | មិនអាចពន្យាពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម ម.២១៤ | ចាប់ពី១៤-ក្រោម១៦ឆ្នាំ | - មិនលើសពី ២ខែ<br>- មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបមារនៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។ | មិនអាចពន្យាពេលឃុំខ្លួនបានឡើយ |

ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីការដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជាអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

សរុបមក ការឃុំខ្លួនបណ្តោះអាសន្នគឺជានីតិវិធីមួយ ដែលធ្វើឡើងនៅក្នុងដំណាក់កាលនៃចៅក្រមស៊ើបសួរ ដែលសម្រេចឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណាទៅលើស្ថានភាពនៃជនត្រូវចោទ ឬលក្ខណៈនៃបទល្មើសនោះ។ ការសម្រេចឃុំខ្លួនបណ្តោះអាសន្នធ្វើឡើងដើម្បីរក្សាសណ្តាប់ធ្នាប់ ធានាដំណើរការនីតិវិធីប្រកបដោយរលូន និងត្រឹមត្រូវ និងការពារមានផលប៉ះពាល់មិនល្អ ដែលកើតឡើងពីជនត្រូវចោទដែលនៅក្រៅការឃុំខ្លួន ជាដើម ។

### ៥.ការដោះលែងឲ្យនៅក្រៅឃុំ

ក្រោយពីពិនិត្យអំពីលទ្ធភាពរបស់អនីតិជនដែលបានប្រព្រឹត្តបទល្មើស ចៅក្រមអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ប្រសិនបើចៅក្រមរកឃើញថាអនីតិជននោះមិនបាន

ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស។ នៅពេលដែលចៅក្រមស៊ើបសួរមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។

## ផ្នែកទី៤៖ ដំណាក់កាលសវនាការ (ចៅក្រមជំនុំជម្រះ)

ការជម្រះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន (មាត្រា ១២៩ នៃរដ្ឋធម្មនុញ្ញ)។ ដំណាក់កាលជំនុំជម្រះជាដំណាក់កាលដ៏សំខាន់មួយ បន្ទាប់ពីដំណាក់កាលស៊ើបសួរបានបញ្ចប់ទៅ។ ការជំនុំជម្រះក្ដីទាក់ទងនឹងអនីតិជន ច្បាប់បានកំណត់ និងបែងចែកពីនីតិវិធីជម្រះខុសពីមនុស្សពេញវ័យ។ យោងតាមមាត្រា ៥១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ អំណាចគ្រប់គ្រងរដ្ឋត្រូវបានបែងចែកជាបីដាច់ដោយឡែកពីគ្នា គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ តុលាការគឺជា ស្ថាប័នឯករាជ្យមួយ ដែលមានអំណាចក្នុងការជំនុំជម្រះគ្រប់រឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង។ អំណាចតុលាការត្រូវបានអនុវត្តតាមរយៈសាលាជម្រះក្ដី ដែលត្រូវបានបែងចែកជាពីរជាន់ គឺ សាលាជម្រះក្ដីជាន់ទាប (១) មានសាលាដំបូង និងសាលាជម្រះក្ដីជាន់ខ្ពស់ (២) មានសាលាឧទ្ធរណ៍ និងតុលាការកំពូល នេះបើយោងតាមមាត្រា ៣ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ។

### ១.សមត្ថកិច្ចរបស់តុលាការជាន់ទាប

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី។[28] ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលការប្រើប្រាស់របាំក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្ដាប់ចម្លើយ។ ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប។ ប៉ុន្តែ ចំពោះបទលហុដែលជនជាប់ចោទជាអនីតិជន គឺសាលាដំបូងសម្រេចឲ្យមានចៅក្រមទោល (ម្នាក់) ដើម្បីធ្វើការជំនុំជម្រះ។

នៅពេលដែលមានរឿងក្ដីព្រហ្មទណ្ឌកើតឡើង តុលាការត្រូវលើកយករឿងក្ដីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្ដីអនីតិជនដែលជាប់ឃុំខ្លួនបណ្ដោះអាសន្ន។ ដើម្បីជាឧត្ដមប្រយោជន៍របស់អនីតិជនក្នុងពេលរងចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឲ្យមានសេរីភាព។

[28] មាត្រា ៤៨ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ករណីដែលរឿងក្តី ត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព។[29]

មុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។ ករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះ តាមត្រូវការ។[30] នៅក្នុងដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ។ បន្ទាប់ពីឆ្លងកាត់នីតិវិធី ការពិភាក្សាដេញដោលនៅក្នុងសវនាការ តុលាការត្រូវ ប្រកាសសាលក្រម នៅពេលសវនាការ ឬនៅពេលសវនាការលើកក្រោយ។ ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។ នៅក្នុងមាត្រា ៥៤ កថាខណ្ឌទី ៣ ក៏បានបញ្ជាក់ផងដែរថា សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន។

### ២.សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់

សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវតែលើកយករឿងក្តីរបស់អនីតិជនមកចាត់ការ ជំនុំជម្រះជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំ ដូចនៅសាលាដំបូងដែរ។ ចំពោះរឿងក្តីដែលអនីតិជនជាប់ឃុំត្រូវយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែ យ៉ាងយូរ គិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសន្យានុម័តដែលមិនអាចជម្នះបាន។ ចំពោះអំណាចក្នុងការបង្វែររបស់សាលាឧទ្ធរណ៍ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ៥២ (អំណាចរបស់តុលាការក្នុងការបង្វែរ)។ សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប។

អនុទ្បោមតាមមាត្រា ៥៦ កថាខណ្ឌទី ១ បានប្បញ្ញត្តិអំពីការបញ្ជូនសំណុំរឿងពីសាលាដំបូងទៅសាលាឧទ្ធរណ៍ និងការបញ្ជូនសំណុំរឿងពីសាលាឧទ្ធរណ៍ទៅតុលាការកំពូល៖

- ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន។

[29] មាត្រា ៤៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[30] មាត្រា ៤៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ករណីដែលមានបណ្ដឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅតុលាការកំពូល ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្ដឹងសាទុក្ខ លើកលែងតែងមានកាលៈទេសៈមិនអាចជម្នះបាន ដែលត្រូវមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន។[31]

វិធានការដែលអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធានការនោះមានការផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់។[32] សាលាឧទ្ធរណ៍ធ្វើការសម្រេចសេចក្ដីដោយពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់។ ឆ្លងកាត់នីតិវិធីជំនុំជម្រះ សាលាឧទ្ធរណ៍ត្រូវចេញសេចក្ដីសម្រេចចុងក្រោយរបស់ខ្លួន ដែលហៅថា «សាលដីកា» ។ ភាគីដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចដែលមានក្នុងសាលដីការបស់សាលាឧទ្ធរណ៍ អាចប្ដឹងសាទុក្ខទៅតុលាការកំពូល តាមកំណត់ច្បាប់។ តុលាការកំពូលគឺជាសាលាជម្រះក្ដីជាន់ខ្ពស់ និងចុងក្រោយបង្អស់។ សេចក្ដីសម្រេចរបស់តុលាការកំពូល គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។ តុលាការកំពូលមានតែមួយគត់ និងមានទីតាំងនៅរាជធានីភ្នំពេញ។ សមាសភាពតុលាការកំពូលរួមមាន ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត។ តុលាការកំពូលមានការបែងចែកជាសភាជំនាញ និងមានស្ថាប័នមហាអយ្យការនៅអមដូចសាលាឧទ្ធរណ៍ផងដែរ។ តុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្ដឹងសាទុក្ខ ដែលមានចៅក្រមចំនួន ០៥រូប រួមមានប្រធាន ០១ រូប និងចៅក្រមប្រឹក្សាចំនួន ០៤ រូប ដោយពិនិត្យ និងសម្រេចទៅលើតែអង្គច្បាប់ប៉ុណ្ណោះ។ ក្នុងករណីមានបណ្ដឹងសាទុក្ខលើកទី២ តុលាការកំពូលធ្វើការជំនុំជម្រះដោយពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ដោយមានចៅក្រមចំនួន ០៩ រូប ក្នុងនោះមានប្រធាន ០១ រូប និងចៅក្រមប្រឹក្សា ០៨ រូប ដែលការជំនុំជម្រះនេះ ហៅថា សភាពេញអង្គ ឬ ការជំនុំជម្រះរួមក្រុម។ សេចក្ដីសម្រេចចុងក្រោយរបស់តុលាការកំពូលហៅថា "សាលដីកា" ដែលជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា និងមានលក្ខណៈស្ថាពរ ។

ទោះបីយ៉ាងណាក៏ដោយ ច្បាប់បានបើកផ្លូវឲ្យមានការប្ដឹងជំនុំជម្រះសាជាថ្មី ឬ ជំនុំជម្រះឡើងវិញចំពោះសេចក្ដីសម្រេចស្ថាពរផងដែរ ដោយត្រូវបំពេញតាមលក្ខខណ្ឌដែលមានកំណត់ដោយច្បាប់។

[31] មាត្រា ៥៦ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[32] មាត្រា ៥៩ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# ជំពូកទី៣
# ការអនុវត្តទោសចំពោះអនីតិជន

# ជំពូកទី៣

# ការអនុវត្តទោសចំពោះអនីតិជន

ការអនុវត្តទោស គឺជាដំណើការនៃការអនុវត្តតាមនីតិវិធីដែលតុលាការបានធ្វើការផ្តន្ទាទោសចំពោះជនល្មើស ពោលគឺនៅក្រោយពេលតុលាការធ្វើការប្រកាសទណ្ឌកម្មចំពោះទណ្ឌិតណាម្នាក់រួចហើយ។ យោងតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន រាល់ការអនុវត្តទោសចំពោះអនីតិជន គឺធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទាដល់អនីតិជននោះតែប៉ុណ្ណោះ ហើយអនីតិជនមិនអាចត្រូវធ្វើការឃុំខ្លួន ឬអនុវត្តទោសដូចទៅនឹងនីតិជនឡើយ។ រាល់ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទា ជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឲ្យអនីតិជនក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ។[33] ដោយឡែក ថ្វីត្បិតតែច្បាប់បានបញ្ញត្តិមកមានគោលបំណងបែបនេះក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គេពុំទាន់ឃើញមាននូវមណ្ឌលនីតិសម្បទាសម្រាប់អនុវត្តទោសចំពោះអនីតិជននៅឡើយ។ ជាមួយគ្នានេះដែរ ច្បាប់ស្តីពីយុត្តិធម៌នីតិជនដដែលនេះ ក៏បានបញ្ញត្តិផ្តល់សិទ្ធិដល់តុលាការក្នុងការប្រកាសទោសចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសក្នុងស្ថានភាពបែបនេះផងដែរ ដែលមានបញ្ញត្តិនៅមាត្រា ៨៨ កថាខណ្ឌទី ១ ដែលមានខ្លឹមសារ “ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា”។ ដូច្នេះ ការអនុវត្តទោសចំពោះអនីតិជន ក្នុងស្ថានភាពបច្ចុប្បន្ននឹងប្រព្រឹត្តទៅមានលក្ខណៈដូចខាងក្រោម៖

## ផ្នែកទី១៖ ការអនុវត្តទោសពិន័យចំពោះអនីតិជន

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ ជំពូកទី ៦ មាត្រា ១៦០ បានចែងអំពីមូលទោសដែលត្រូវអនុវត្តចំពោះអនីតិជនចាប់ពីអាយុ ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ចំពោះអប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយប្រភេទដែលស្ថិតក្នុងឋានៈជាមូលទោស ហើយខុសពីទណ្ឌកម្មផ្សេងៗទៀតដែលចៅក្រមបានធ្វើការផ្តន្ទាទោស ពោលគឺសំដៅទៅលើទោសមួយប្រភេទដែលមានគោលដៅធ្វើឲ្យជនល្មើសនោះមានការរាងចាលតែម្តង។

### ១.ការដាស់តឿនឲ្យបង់ប្រាក់ពិន័យ

ជាទូទៅ ប្រសិនបើដល់ការកំណត់ដែលត្រូវបង់ប្រាក់ពិន័យ ហើយទណ្ឌិតមិនបានបង់ទេនោះ អង្គភាពរតនាគារត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ក្រោយពីបានទទួលដំណឹងនេះហើយ ព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់មួយសម្រាប់ទុកដល់ទណ្ឌិតដែលជាអនីតិជននោះ ដើម្បីឲ្យបង់ប្រាក់ពិន័យ។ រីឯចំពោះរយៈពេលដែលព្រះរាជអាជ្ញាបានកំណត់នោះមិនអាចតិចជាង ១០ ថ្ងៃឡើយ។ មិនតែប៉ុណ្ណោះ ការជូនដំណឹងនេះទៀតសោធន៍ ចាំបាច់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ

[33] មាត្រា ៧៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ផងដែរ។ លើសពីនេះទៅទៀត ការឲ្យដំណឹងនេះត្រូវតែមានការធ្វើជាកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយទណ្ឌិត ឬផ្តិតម្រាមដៃ ក្នុងករណីដែលទណ្ឌិតមិនចេះចុះហត្ថលេខា។

សូមបញ្ជាក់ផងដែរថា ទោះបីជាមានការជូនដំណឹងដោយព្រះរាជអាជ្ញា អំពីការដាស់តឿនឲ្យទណ្ឌិតដែលជាអនីតិជននោះនៅតែមិនព្រមបង់ប្រាក់ពិន័យទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយចំពោះអនីតិជននោះបានឡើយ។

### ២.ការរួចផុតពីការបង្ខំដល់រូបកាយ

ការបង្ខំរូបកាយមានលក្ខខណ្ឌដូចគ្នានឹងអ្នកជាប់ទោសពន្ធនាគារដែរ។[34] ការបង្ខំលើរូបកាយមិនធ្វើលើទណ្ឌិតជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ (ហុបសិបប្រាំ) ឆ្នាំ ឡើងទៅ និងទៅលើបុរសអាយុចាប់ពី ៧០ (ចិតសិប) ឆ្នាំ ឡើងទៅបានឡើយ។ មួយវិញទៀត ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាលើប្តី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ។ នៅពេលអនីតិជនបានប្រព្រឹត្តបទល្មើសដែលធ្វើឲ្យមានព្យសនកម្មបះពាល់ដល់ស្ត្រី ឬបុរសដែលមានវ័យចាស់ជរា ច្បាប់សម្រេចលើកលែងទោសដល់អនីតិជនដែលបានប្រព្រឹត្តបទល្មើសនោះ។ ដូច្នេះ ក្នុងករណីអនីតិជនម្នាក់បានប្រព្រឹត្តបទល្មើស ចៅក្រមអាចប្រកាសឲ្យអនីតិជននោះបង់សំណងចូលថវិការរដ្ឋផង និងសម្រេចឲ្យបង់សំណងរដ្ឋប្បវេណីទៅជនរងគ្រោះផងដែរ។ ដើម្បីអាចធានាបាននូវការបង់ប្រាក់ពិន័យ វិធានការទូទៅដែលត្រូវលើកយកមកអនុវត្តចំពោះទណ្ឌិតដែលជាអនីតិជននោះ គឺការដាស់តឿនអោយបង់ប្រាក់ពិន័យដោយអាជ្ញាធរតុលាការ។

## ផ្នែកទី២៖ ការអនុវត្តទោសដាក់ពន្ធនាគារចំពោះអនីតិជន

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ឲ្យបានច្បាស់លាស់ឡើយអំពីពាក្យថាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដូចនេះនៅពេលជួបប្រទះនូវករណីណាមួយ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការដែលគេហៅម្យ៉ាងទៀតថា ឆន្ទានុសិទ្ធិ ក្នុងការគិតពិចារណាថា តើអនីតិជននោះត្រូវទទួលខុសត្រូវ ឬក៏អត់ចំពោះទង្វើល្មើសច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។ ទោសដាក់ពន្ធនាគារ សំដៅដល់កន្លែងប្រើប្រាស់សម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង។[35] ការដាក់ពន្ធនាគារ អនីតិជនដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ត្រូវតែជាវិធានការចុងក្រោយបង្អស់ ដែលត្រូវបានប្រើតែក្នុងករណីពិសេសតែប៉ុណ្ណោះ។[36] គោលបំណងចម្បងក្នុងការអនុវត្តទោសចំពោះ អនីតិជនក្នុងពន្ធនាគារ គឺដើម្បីធ្វើការអប់រំ កែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាដល់ទណ្ឌិតដែលជាអនីតិជននោះតែប៉ុណ្ណោះ។ ក្នុងគោលដៅដើម្បី ក្រោយពីកាអនុវត្តទោសត្រូវបានបញ្ចប់រួចហើយ អាចឲ្យអនីតិជននោះចូលមករួមរស់នៅក្នុងសង្គមវិញ។

---

[34] មាត្រា ៥២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[35] មាត្រា ៤ ចំណុច ១ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ ២០១១

[36] មាត្រា ៣៧ ចំណុច(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

ទិដ្ឋភាពក្នុងការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារនោះនឹងត្រូវបង្ហាញតាមរយៈពីរចំណុចសំខាន់ៗដូចខាងក្រោម៖

**១.ការអនុវត្តទោសចំពោះអនីតិជនអាយុក្រោម ១៤ ឆ្នាំ**

ជាទូទៅ រាល់អនីតិជនដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសទាំងអស់ តុលាការមិនអាចសម្រេចផ្តន្ទាទោសលើអនីតិជនប្រភេទនេះបានឡើយ។ ដូច្នេះហើយ តុលាការអាចប្រកាសទោសព្រហ្មទណ្ឌលើអនីតិជនបាន លុះត្រាតែអនីតិជននោះមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ដោយគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។ ថ្វីត្បិតតែអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែពុំមែនមានន័យថា ច្បាប់មិនអើពើ ឬ មិនយកចិត្តទុកដាក់ និងពុំមានវិធានការអ្វីមួយអនុវត្តចំពោះអនីតិជននោះឡើយ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីវិធានការផ្សេងៗ ដើម្បីអាចយកមកអនុវត្តចំពោះអនីតិជនទាំងនោះ។ អនីតិជនដែលបានប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដោយប្រភេទនៃវិធានការនេះ មានដូចខាងក្រោម៖

- ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល ឬបុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសម។ បើទោះបីជាអនីតិជនស្ថិតនៅដំណាក់កាលនៃនីតិវិធីរបស់តុលាការក៏ដោយ បើអនីតិជនត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតចាប់ពីថ្ងៃដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស អនីតិជនពុំអាចត្រូវបានគេឃាត់ខ្លួន ឬត្រូវតម្កល់រឿងទុកឥតចាត់ការ ឬមិនអាចឃុំខ្លួនបណ្តោះអាសន្នបានឡើយ ហើយត្រូវប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ។

- ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលទទួលបន្ទុកថែទាំអនីតិជន។

- ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជនដែលមាននីតិសម្បទា ក្នុងការទទួលអនីតិជន។

- ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។ ក្នុងករណីអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅនឹងសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ មន្ទីរ ឬការិយាល័យបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជន។

- ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ តុលាការត្រូវចាត់តាំងបុគ្គលមួយរូបឲ្យទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះត្រូវផ្តល់ព័ត៌មានជូនដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការនេះ។

គួរកត់សម្គាល់៖ តុលាការជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចាត់ចែងវិធានការដែលបានរៀបរាប់ខាងលើ។ ប៉ុន្តែក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានចែងលម្អិតអំពីនីតិវិធីពិសេស សម្រាប់ការចាត់វិធានការទាំងអស់នេះឲ្យមានប្រសិទ្ធិភាពនោះទេ។ ផ្ទុយទៅវិញច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ បានប្បញ្ញត្តិពីយន្តការ និងនីតិវិធី

យ៉ាងច្បាស់លាស់ក្នុងការប្រគល់អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលបានសង្ស័យថាបានប្រព្រឹត្តបទល្មើស ទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬឲ្យឯកទេសដែលបានទទួលនីតិសម្បទាក្នុងការថែរក្សាអនីតិជន ដែលបានប្រព្រឹត្តបទល្មើស។

## ២.ការអនុវត្តទោសចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

ករណីដែលតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថាទោសដែលត្រូវអនុវត្តចំពោះអនីតិជនគឺត្រូវបានផ្តោតទៅលើគោលការណ៍៤៖

- ទោសដែលខ្ពស់បំផុត ឬអតិបរិមានៃទោស ត្រូវបន្ថយមកត្រឹមពាក់កណ្តាល
- ប្រសិនបើមានការជាប់ពន្ធធនាគារអស់មួយជីវិតវិញ ត្រូវបន្ថយមកត្រឹម២០ឆ្នាំ
- ទោសដែលទាបបំផុត ឬអប្បបរិមានៃទោស មានរយៈពេលលើសពី១ថ្ងៃឡើងទៅ ត្រូវថយមកត្រឹមពាក់កណ្តាលវិញ
- សម្រាប់ទោសពិន័យជាប្រាក់ក៏ត្រូវបន្ថយមកត្រឹមពាក់កណ្តាលដែរ ទោះបីជាស្ថិតនៅក្នុងអតិបរិមានៃទោស ឬ អប្បបរិមានៃទោសក៏ដោយ។

ក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបញ្ញត្តិនៃមាត្រានេះមាន អានុភាពបន្ថយ អតិបរមានៃទោសដាក់ពន្ធនាគារ មកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។ ក្រៅពីមូលទោស តុលាការក៏អាចប្រកាសទោសបន្ថែម និងទោសការងារសហគមន៍បានផងដែរ ដែលចំណុចនេះមាន បញ្ញត្តិនៅក្នុងមាត្រា ១៦១ និង១៦២ នៃក្រមព្រហ្មទណ្ឌ។

នៅក្នុងមាត្រា ១៦៤ បានចែងថា ប្រសិនបើតុលាការសម្រេចឲ្យមានស្ថានសម្រាលទោស អប្បបរិមានៃទោសទៅលើ អនីតិជនចំពោះបទឧក្រិដ្ឋព្រហ្មទណ្ឌក៏ដោយ បទមជ្ឈឹមក៏ដោយ គឺត្រូវមានការបន្ថយទោសដូចតទៅ៖

- បើជាប់ពន្ធធនាគារស្មើ ឬលើស ១០ (ដប់) ឆ្នាំ ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ។
- បើជាប់ពន្ធធនាគារស្មើ ឬលើស ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ។
- បើជាប់ពន្ធធនាគារស្មើ ឬលើស ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ។
- បើជាប់ពន្ធធនាគារស្មើ ឬលើស ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ ត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ។
- ចំពោះប្រាក់ពិន័យត្រូវកាត់បន្ថយពាក់កណ្តាល។[37]

ចំពោះការឃុំឃាំងអនីតិជនវិញ គឺមានភាពខុសគ្នាពីការឃុំឃាំងនីតិជន។ ក្នុងមាត្រា ១៦៦ បានប្បញ្ញត្តិថា បើ អនីតិជនត្រូវជាប់ពន្ធធនាគារ កន្លែងឃុំឃាំងត្រូវនៅដាច់ដោយឡែកពីនីតិជន។ អនីតិជនត្រូវស្ថិតនៅក្រោមរបបដោយ ឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ។ របបឃុំឃាំងត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ។

[37] មាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧

- សរុបមកអោយតែមានការប្រព្រឹត្តបទល្មើសអ្វីមួយកើតឡើង ពិតណាស់វាតែងបង្កឲ្យមានព្យសនកម្ម ឬក៏ហៅម្យ៉ាងទៀតថាជាការខូចខាត ផ្សេងៗ ដែលជាមូលហេតុមួយតម្រូវឲ្យមាន ការទទួលខុសត្រូវចំពោះអំពើ និងផលដែលខ្លួនបានប្រព្រឹត្តិចំពោះបុគ្គលដែលយើងបានជះផលទៅឲ្យ។ ប៉ុន្តែ ជាបទប្បញ្ញត្តិដោយឡែក ច្បាប់ក៏បានកំណត់នូវគោលការណ៍នៃការ ទទួលខុសត្រូវព្រហ្មទណ្ឌមួយដាច់ដោយឡែក សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើសផងដែរ ដើម្បីជាការការពារអនីតិជនដើម្បីកុំឲ្យប៉ះពាល់ទៅដល់សិទ្ធិ ក៏ដូចជាបង្កនូវការលំបាកដល់ អនីតិជនដែលជាគោលការណ៍អនីតិជនត្រូវបានគាំពារយ៉ាងខ្លាំងដោយច្បាប់ ជាពិសេសនោះគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងធ្វើការបកស្រាយខាងលើរួចមក យើងអាចសង្កេតឃើញ និងសន្និដ្ឋានបានថា អនីតិជនគឺជាជនដែលត្រូវបានកម្រិតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ គ្រប់អនីតិជនទាំងអស់ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ប៉ុន្តែដោយហេតុថា អនីតិជនពុំមានសមត្ថភាពយល់ដឹងអំពីអំពើរបស់ខ្លួនទាំងស្រុង ព្រមទាំងស្ថិតនៅក្នុងវ័យកំពុងលូតលាស់ និងអភិវឌ្ឍន៍ផ្នែកគំនិត ប្រាជ្ញាស្មារតី និងការគិតពិចារណារបស់ពួកគេនៅក្មេងខ្ចីនៅឡើយ។ ទាំងអស់នេះហើយដែលជាកត្តានាំឲ្យចៅក្រមពិនិត្យទៅលើអាយុរបស់អនីតិជនដែលបានប្រព្រឹត្តបទល្មើស ដើម្បីកំណត់បានថា តើអនីតិជននោះមានលទ្ធភាពក្នុងការទទួលព្រហ្មទណ្ឌហើយឬនៅ? ចំណុចទាំងនោះរួមមានដូចជា កត្តាអាយុ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជន។ ចៅក្រម និងតំណាងអយ្យការត្រូវយកកត្តាទាំងអស់នេះមកពិចារណាឲ្យបានល្អិតល្អន់ និងម៉ត់ចត់បំផុតមុននឹងធ្វើការសន្មតថាអនីតិជនត្រូវខុសត្រូវព្រហ្មទណ្ឌ ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ? ព្រោះថា ប្រសិនបើចៅក្រម និងតំណាងអយ្យការពុំបានធ្វើការពិចារណាឲ្យបានល្អិតល្អន់ និងម៉ត់ចត់បំផុតនោះទេ វានឹងអាចជះឥទ្ធិពលអាក្រក់ទៅលើអនាគតរបស់អនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាខ្លាំង។

ក្នុងច្បាប់ក៏បានបញ្ញត្តិនូវវិធានការក្នុងការអនុវត្តចំពោះអនីតិជន ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដោយគិតគូទៅដល់ឧត្តមប្រយោជន៍កុមារ ធ្វើអោយគ្រប់នីតិវិធីដែលពាក់ព័ន្ធនឹងអនីតិជនប្រព្រឹត្តបទល្មើសមានលក្ខណៈកុមារមេត្រីជាពិសេសស្របទៅតាមអនុសញ្ញាជាសកលស្តីពីសិទ្ធិកុមារ និងលិខិតតុបករណ៍អន្តរជាតិនានា។ វិធានការទាំងនោះរួមមាន ទណ្ឌកម្មព្រហ្មទណ្ឌ និងវិធានការបង្វែរ។ វិធានការបង្វែរគឺជាវិធានការថ្មីមួយដែលមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានប្រកាលឲ្យប្រើកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលវិធានការនេះតម្រូវឲ្យព្រះរាជអាជ្ញាក៏ដូចជាចៅក្រមត្រូវពិចារណាទៅលើការបង្វែរអនីតិជនដែលបានប្រព្រឹត្តបទល្មើស ហើយអនីតិជននោះបានសារភាពថាបានប្រព្រឹត្តបទល្មើសចេញពីនីតិវិធីតុលាការ ក្នុងន័យលើកទឹកចិត្ត ចៀសវាងនូវស្នាមអាក្រក់ដក់ជាប់ក្នុងអារម្មណ៍ បង្ការការរើសអើងទៅលើអនីតិជន និងចៀសវាងការមានប្រវត្តជាប់ទោស ក្នុងបញ្ជីថ្កោលទោស។ រីឯ វិធានទណ្ឌកម្មទព្រហ្មទណ្ឌវិញ ចាំបាច់ត្រូវតែជាវិធានការចុងក្រោយបំផុតសម្រាប់យកមកអនុវត្តចំពោះអនីតិជន។ រាល់នីតិវិធីដែលអនុវត្តចំពោះអនីតិជន ត្រូវតែជានីតិវិធីដែលមានលក្ខណៈកុមារមេត្រី ហើយទោសដែលអនុវត្ត ត្រូវកម្រិតមកត្រឹមពាក់កណ្តាលនៃទោសដែលអនុវត្តចំពោះនីតិជន។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងបកស្រាយចំពោះប្រធានបទខាងលើ យើងខ្ញុំសូមចូលរួមធ្វើការផ្តល់ជាអនុសាសន៍មួយចំនួន ក្នុងគោលបំណងដើម្បីឲ្យការអនុវត្តទោសចំពោះអនីតិជនកាន់តែមានប្រសិទ្ធភាពដូចតាមការកំណត់នៅក្នុងទ្រឹស្តី និងទទួលបានជំនឿទុកចិត្តពីសាធារណៈជន ក៏ដូចជាជនត្រូវចោទជាអនីតិជនលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ចំពោះអនុសាសន៍ទាំងនោះរួមមានដូចខាងក្រោម៖

នៅក្នុងការអនុវត្តជាក់ស្តែងសព្វថ្ងៃ យើងឃើញថា ទោះបីជាច្បាប់បានបញ្ញត្តិការពារសិទ្ធិ និងការពារឧត្តមប្រយោជន៍របស់អនីតិជនខ្លាំងយ៉ាងណាក៏ដោយ ក៏ការអនុវត្តនៅមានភាពខ្វះចន្លោះ និងកង្វះខាតនៅឡើយ។ ដើម្បីឆ្លើយតបទៅនឹងប្រធានបទនេះ ព្រមទាំងដើម្បីឲ្យការអនុវត្តជាក់ស្តែងពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន មានភាពត្រឹមត្រូវ ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍ ព្រមទាំងការផ្តល់យុត្តិធម៌ដល់អនីតិជន។ យើងខ្ញុំសូមផ្តល់ជាមតិយោបល់ និងលើកឡើងអំពីសំណូមពរ ដូចខាងក្រោម៖

- នៅក្នុងនីតិវិធីនគរបាលយុត្តិធម៌ ចំបាច់ត្រូវតែជានគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ជាអ្នកធ្វើការត្រួតពិនិត្យ កំណត់អត្តសញ្ញាណ ចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន ព្រមទាំងប្រមូលភស្តុតាង។
- នៅក្នុងដំណាក់កាលចោទប្រកាន់ ដែលជាសមត្ថកិច្ចរបស់អង្គការអយ្យការត្រូវប្រគល់ឲ្យទៅតំណាងអយ្យការដែលទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន។
- ពង្រឹងការអនុវត្តនីតិវិធីគ្រប់ដំណាក់កាល និងត្រូវប្រាកដថា នីតិវិធីដែលប្រព្រឹត្តលើអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈជានីតិវិធីកុមារមេត្រី ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
- បង្កើតតុលាការអនីតិជន ដែលមានមន្ត្រីជំនាញធ្វើការលើរឿងក្តីរបស់អនីតិជន។
- ផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធទៅនឹងអនីតិជនឲ្យបានទូលំទូលាយ ទៅគ្រប់មជ្ឈដ្ឋានទាំងអាជ្ញាធរ និងប្រជាពលរដ្ឋ ក៏ដូចជាអង្គការនានា។
- លើកទឹកចិត្ត និងជម្រុងអោយព្រះរាជអាជ្ញា និងចៅក្រមពិចារណាជាបឋមទៅលើវិធានការបង្វែរ មុននឹងប្រើប្រាស់នូវវិធានការដទៃ សម្រាប់ជាឧត្តមប្រយោជន៍របស់អនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។
- ប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវធ្វើការណែនាំមន្ត្រីពន្ធនាគារនៅតាមតំបន់សមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ចំពោះការដាក់ជនជាប់ឃុំដែលជាអនីតិជន អោយនៅដាច់ដោយឡែកពីនីតិជនដោយយកចិត្តទុកដាក់បំផុត។

# ឯកសារយោង

# ឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
- គោលការណ៍ស្តីពី យុត្តិធម៌អនីតិជន ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៥
- អនុសញ្ញាស្តីពីសិទ្ធិកុមារ  ឆ្នាំ២០០៩
- ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១
- សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ មីន សំអុល បោះពុម្ពឆ្នាំ២០១៧

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

...រឿងព្រហ្មទណ្ឌលេខ .........

...ទី ១៣ ខែសីហា ឆ្នាំ ២០១៩

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

...............អ.យ. យើង ............... ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ........... ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ របស់អយ្យ ការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សរុបលេខ ២៨៨ លស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន ផែនការងារនគរបាលព្រហ្មទណ្ឌ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១-នាមត្រកូល-នាមខ្លួន:.................... ភេទប្រុស អាយុ ១៧ឆ្នាំ , ជនជាតិខ្មែរ ,កាន់សាសនាព្រះពុទ្ធ , មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ, ជាអនីតិជន ។ (ក្នុងឃុំ)

២- ឈ្មោះ.........ភេទប្រុស អាយុ១៧ឆ្នាំ (គេចខ្លួន)។

៣- ម្ចាស់ហាងទទួលបញ្ចាំ (គេចខ្លួន)។

**ប្រព្រឹត្តអំពើដូចតទៅ៖**កាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០១៩ វេលាម៉ោង១១និង០០នាទី ជនសង្ស័យ ឈ្មោះ............... បានខ្ចីម៉ូតូ ម៉ាក ZOOMER-Xពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1GJ-8423ពីជនរងគ្រោះឈ្មោះ.............. ភេទស្រី អាយុ១៩ឆ្នាំ នៅចំណុច .........ផ្ទះលេខ .........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ ដោយប្រាប់ថាយកទៅដកលុយរៀង ហើយជនរងគ្រោះក៏យល់ព្រមឲ្យ បន្ទាប់មកជនសង្ស័យក៏បានយកម៉ូតូនោះទៅឲ្យឈ្មោះ...........ជាមិត្តភ័ក្ត្ររបស់ខ្លួន ដាក់បញ្ចាំនៅហាងម៉ុស្តូបទេពផន បានលុយចំនួន៥០០ (ប្រាំរយដុល្លារអាមេរិក)$ យកមកចែកគ្នា។ រហូតដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៩ ជនសង្ស័យបានមកចំណុចកើតហេតុខាងលើក៏ត្រូវជនរងគ្រោះឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍រដ្ឋបាលទន្លេបាសាក់ដើម្បីចាត់ការតាមនីតិវិធីតែម្តង។

អំពើខាងលើជាបទល្មើស ៖ រំលោភលើទំនុកចិត្ត និងទទួលផលចោរកម្ម ប្រព្រឹត្តនៅ នៅចំណុច .........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១,៣៩២និងមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញៈ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖**

☑ ដាក់ស្ថិតក្រោមការពិនិត្យ[24] ៖

១-ឈ្មោះ ..................ភេទ ប្រុស អាយុ ១៧ ឆ្នាំ(ក្នុងឃុំ) ។

២-ឈ្មោះ ..................ភេទប្រុស អាយុ១៧ឆ្នាំ (គេចខ្លួន)។

៣- ម្ចាស់ហាងទទួលបញ្ចាំ (គេចខ្លួន)។

ពីបទ៖ រំលោភលើទំនុកចិត្ត និងទទួលផលចោរកម្ម ប្រព្រឹត្តនៅ នៅចំណុច .........ផ្ទះលេខ .........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១,៣៩២ និងមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[25]

..........................................

☑ ដាក់ឱ្យស្ថិតនៅការឃុំខ្លួនបណ្តោះអាសន្ន ៖

-ឈ្មោះ..................ភេទ ប្រុស អាយុ១៧ឆ្នាំ ។( ក្នុងឃុំ)

ថ្ងៃសុក្រ ១៣ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៩

**ជ.ព្រះរាជអាជ្ញា**

---

[២៤]ឈ្មោះជនត្រូវចោទ

[២៥] កាតព្វកិច្ចណាមួយដែលបានចែងក្នុងមាត្រា ២២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៨៣, ១៨៤, ២៨០ និងមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

**សាលាដំបូងរាជធានីភ្នំពេញ**
បន្ទប់ស៊ើបសួរ "....."
រឿងលេខៈ........../១៣.០៨.១៩
ស៊ើបសួរៈ /១៥.០៨.១៩

ឆ្នាំពីរពាន់ដប់ម្ភៃ ខែមករា ថ្ងៃទីដប់ វេលាម៉ោងប្រាំបួននិងសូន្យនាទីព្រឹក។

**យើង ..................ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។**

អមដោយលោក ................ ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ។

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទនៅចំពោះមុខយើងជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

ឈ្មោះ ........... ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ ឪពុកឈ្មោះ ......... "ស" ម្តាយឈ្មោះ ........"រ" ជាអនីតិជន ទោសគ្មានពីមុន។

តើអ្នកចេះអាន និងសរសេរភាសារខ្មែរដែរ ឬទេ?

ខ្ញុំបាទអាន និងសរសេរបានខ្លះ

☐ជននេះបានប្រកាសថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម១០(ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវនីមួយៗ ដែលព្រះរាជអាជ្ញាបានប្តឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ........ អ.យ..... ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១៩ ដែលជាហេតុនាំឲ្យមានការបង្ហាញខ្លួនជននេះនៅចំពោះមុខយើងព្រមទាំងប្រាប់ជននេះឲ្យដឹងអំពីបទចោទប្រកាន់ចំពោះរឿងរ៉ាវដូចខាងក្រោមៈ

តំណាងអយ្យការបានចោទប្រកាន់អ្នកឯងពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច .........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

យើងបានជូនដំណឹងដល់ជននេះថា យើងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យ ចំពោះរឿងរ៉ាវដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់ ។

លោក................................ ជាមេធាវី នៃជនត្រូវចោទ ដែលត្រូវបានកោះហៅនៅថ្ងៃទី.............................................ហើយដើម្បីឲ្យ លោក-លោកស្រីមេធាវី អាចត្រៀមរៀបចំការពារក្តីខ្លួនបាន ។

យើងបានប្រាប់ដល់ជននេះអំពី ៖

សិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសពឹងពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យតុលាការចាត់តាំងមេធាវីណាម្នាក់ឲ្យ ។

ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូបនឹងត្រូវចាត់តាំងដោយឯកឯងដោយសារតែជននេះ ជាអនីតិជន ។

ជននេះ បានប្រកាសប្រាប់ថា ៖ □ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង □ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវី មួយរូបឲ្យខ្ញុំ □ ខ្ញុំបដិសេធជំនួសពីមេធាវី ។

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬអាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន ។

ជននេះបានប្រកាសថា ៖ខ្លួនអាចឆ្លើយការពារខ្លួនឯង បានដោយមិនចាំ បាច់មានមេធាវី ជំនួយទេ ។

លោកមេធាវី.................. បានផ្តល់សេចក្តីកត់សម្គាល់ការពារថា៖

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ ៖

☑ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង ។

☑ ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ ប្រាប់ជននេះ អំពីឈ្មោះនៃបទល្មើស ។

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹងសុំមោឃភាពនៃកិច្ចស៊ើបសួរដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេលនៃដំណើរការនៃការស៊ើបសួរ ក្នុងលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទអំពើសិទ្ធិក្នុងការជ្រើសមេធាវី សម្រាប់នីតិវិធីបន្ទាប់ មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមានសំណើសុំយើងនឹងចាត់តាំងមេធាវីមួយរូបជន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបាន ជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ ) ។

ជនត្រូវចោទ បានប្រកាសប្រាប់ថា ៖ □ ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង □ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ □ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ជនត្រូវចោទថា អ្នកឯងអាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេល ផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេច ៖

☑ ឃុំខ្លួនបណ្តោះអាសន្ន □ មិនឃុំខ្លួនបណ្តោះអាសន្ន □ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

យើងបានប្រាប់ដល់ជនត្រូវចោទថា ៖

ត្រូវប្រកាសប្រាប់អំពីអាសយដ្ឋានដែលជាអាសយដ្ឋានផ្ទាល់ខ្លួន ឬ ជាអាសយដ្ឋានរបស់ តតិយជនណាម្នាក់ ដែលទទួលបន្ទុកយកលិខិតដែលបញ្ជូនទៅឲ្យ ប្រសិនបើគាត់អាចផ្តល់ឲ្យភ្លាមនូវការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររបស់តតិយជននោះ ។

អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិត

នៅ........................................................................................................

..................................។

អាសយដ្ឋាននេះជា □ អាសយដ្ឋានផ្ទាល់ខ្លួន □ អាសយដ្ឋានរបស់:..........

........................................................................................................

........។

រហូតដល់ការបិទការស៊ើបសួរគាត់ត្រូវប្រាប់ដល់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋានដែលបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ ។

គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋានដែលជនបានប្រកាស ប្រាប់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាជូនដំណឹងដល់បុគ្គលជនត្រូវចោទ ។

☑ យើងបានឲ្យជនត្រូវចោទឲ្យអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

☑ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

☑ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទ។

**ជនត្រូវចោទ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៖៤៤

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "..."

សំណុំរឿងលេខៈ ...../១៣.០៨.១៩

លេខស៊ើបសួរៈ...../១៥.០៨.១៩

## កំណត់ហេតុស្តីពីការដេញដោលចំពោះមុខ

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែសីហា ថ្ងៃទីដប់ប្រាំ វេលាម៉ោងដប់ និងសូន្យនាទីព្រឹក។

**យើង...................... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។**

**អមដោយលោក ..............ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ។**

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

ឈ្មោះ ............ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ ឪពុកឈ្មោះ ......... "ស" ម្តាយឈ្មោះ ........"រ" ជាអនីតិជន ទោសគ្មានពីមុន។

☑ ជននេះ ប្រកាស់ប្រាប់ថា ចេះអាន និងចេះសរសេរភាសាខ្មែរ

☐ ជននេះ ប្រកាសថា មិននេះអាន និងមិនចេះសរសេរភាសាខ្មែរ

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច.........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ........... រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ....អ.យ..... ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

☐ ដោយមានវត្តមានលោក លោកស្រីមេធាវី.......................................................ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួន ☐ ឬ ☐ ដែលត្រូវបានចាត់តាំងដោយគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញខ្លួននៅក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយនឹងជនត្រូវចោទនៅពេលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខយើង ។

☐ដោយមានវត្តមានលោក-លោកស្រី ..............................................ជាអ្នកបកប្រែដែល ត្រូវបានជ្រើសតាំងដោយចៅក្រមស៊ើបសួរ ។

☑យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំ ខ្លួនគាត់ជាបណ្តោះអាសន្ន ។

☑យើងបានប្រាប់ថាជនត្រូវចោទអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន។

☑ យើងបានប្រាប់ថាជនត្រូវអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន ។

☑យើងក៏បញ្ជាប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃនេះ ។

☑ ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា ជនត្រូវចោទមានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬ ពីមេធាវី តាមការចាត់តាំង ។

ជនត្រូវចោទ បានប្រកាសប្រាប់ថា ៖

☐ ខ្ញុំត្រូវការជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង ។

☐ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ ។

☐ លោក, លោកស្រីមេធាវី.................................ត្រូវបានជូនដំណឹងដោយចៅក្រមស៊ើបសួរបន្ទប់លេខ........ អាចពិគ្រោះមើលសំណុំរឿងដែលទុកឲ្យគាត់ពិនិត្យ និងអាចសន្ទនាដោយសេរីជាមួយកូនក្ដីរបស់គាត់ ។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ៖

☑ ត្រូវបានធ្វើ

☑ត្រូវលើកទៅថ្ងៃទី.......... ខែ........ ឆ្នាំ.......... តាមសំណូមពររបស់.................
...................... ។

តំណាងអយ្យការបានបង្ហាញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោម៖

សូមចៅក្រមចាត់ការតាមនីតិវិធី។

ជនត្រូវចោទបានបង្ហាញសេចក្ដីសង្កេតរបស់ខ្លួនដូចខាងក្រោម ៖

សូមមិនអោយតុលាការឃុំខ្លួនខ្ញុំទេ ខ្ញុំសូមសន្យាថានិងចូលខ្លួនគ្រប់នីតិវិធី។

លោក-លោកស្រីមេធាវី..........................................បានបង្ហាញសេចក្ដីសន្និដ្ឋានការពារកូនក្ដីខ្លួនខាងក្រោម ៖

..........................................................................................................
............

យើងបានប្រាប់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះតែម្ដង ។

☑ យើងបានឲ្យជនត្រូវចោទឲ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

☑ បានអាចចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

☑ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

| | | |
|---|---|---|
| **ជនត្រូវចោទ** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ចៅក្រមស៊ើបសួរ "....."

-សំណុំរឿងព្រហ្មទណ្ឌ

លេខ: .....១០/០២/២០

# កំណត់ហេតុ
## ស្តីពីការសួរចម្លើយជនត្រូវចោទ
(មាត្រា១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកុម្ភៈ ថ្ងៃទីដប់ប្រាំ វេលាម៉ោងដប់និងសូន្យនាទីព្រឹក ។

យើង.................ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក ....................ជាក្រឡាបញ្ជី។

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទនៅក្នុងមន្ទីរស៊ើបសួរ ចំពោះមុខយើងជនដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ ....................ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ, ជាអនីតិជន ។ ឪពុកឈ្មោះ ......... "ស" ម្តាយឈ្មោះ ........"រ" ជាអនីតិជន ទោសគ្មានពីមុន។

ផ្តន្ទាទោសដោយតុលាការ៖ **គ្មាន** ។

☐ ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០(ដប់)ឆ្នាំ ដែលស្ថិតនៅទីលំនៅបច្ចុប្បន្ន ។

ជននេះ ៖☑ ចេះនិយាយ ☐ ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

ជននេះ ៖☐មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈ្មោះនេះ យើងបានប្រាប់ដល់ឈ្មោះនេះអោយដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលតំណាងអយ្យការបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ.......... អ.យ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ជាហេតុនាំអោយជននេះត្រូវបានដាក់អោយស្ថិតនៅក្រោមការពិនិត្យ។

យើងបានសួរចម្លើយជននេះ ហើយជននេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា ៖

សួរ.ឆ្លើយ៖ខ្ញុំបាទបានដឹងអំពីតំណាងអយ្យការបានចោទប្រកាន់មកលើខ្ញុំបាទហើយ។

សួរ.ឆ្លើយ៖ នៅពេលនេះខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបានដោយមានមេធាវីអមជាមួយផង។

សួរ.ឆ្លើយ៖ ខ្ញុំបាទ........... សុំបដិសេធចម្លើយនៅដំណាក់កាលអយ្យការ និងចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដោយខ្ញុំបាទសុំបដិសេធនៅត្រង់ចំណុចដែលថាខ្ញុំបាទបានយកម៉ូតូឲ្យទៅឈ្មោះ សេង ហុង យកទៅដាក់បញ្ចាំនៅម្តុំទេពផន បានលុយ៥០០$ រួចយកទៅលេងហ្គេមចាញ់លុយអស់។

សួរ.ឆ្លើយ៖ កាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១០ និង៤០នាទី ខ្ញុំបាទបានសុំខ្ចីម៉ូតូពីឈ្មោះ............ដោយប្រាប់ថាទៅដកលុយមួយភ្លែត តែខ្ញុំមិនបានទៅដកលុយទេដោយសារតែស្ទះផ្លូវពេកក៏បានជិះទៅផ្ទះនៅឬស្សី ពេលខ្ញុំបាទទៅដល់ផ្ទះ មិត្តភ័ក្ត្ររបស់ខ្ញុំបាទឈ្មោះ សេង ហុងបានខ្ចីម៉ូតូនេះទៅទិញអីញ៉ាំ លុះដល់ម៉ោងប្រហែល ៥ល្ងាច ម្តាយរបស់ឈ្មោះសេង ហុង បានយកលុយចំនួន២០០$ មកឲ្យខ្ញុំបាទដោយបានប្រាប់ថាឈ្មោះ សេង ហុងផ្ញើមកឲ្យខ្ញុំ បន្ទាប់មកខ្ញុំបាទក៏បានជិះឡានទៅខេត្តបាត់ដំបងតែម្តងទៅ។

សួរ.ឆ្លើយ៖ជាចុងក្រោយខ្ញុំបាទសំណូមពរលោកចៅក្រមជួយបន្ធូបន្ថយទោសដល់រូបខ្ញុំបាទផង។

**បញ្ឈប់កំណត់ហេតុនេះ នៅវេលាម៉ោងដប់ និងសាមសិបនាទីព្រឹកនាថ្ងៃខែឆ្នាំដូចខាងលើ។**

☒យើងបានអោយជនត្រូវចោទអោយអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ ហេតុនេះហើយបើមិនបដិសេធត្រង់ចំណុចណាទេ អោយចុះហត្ថលេខា ឬផ្តិត ម្រាមដៃលើកំណត់ហេតុនេះ។

☒បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធត្រង់ចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង និងក្រឡាបញ្ជី។

☒បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធត្រង់ចំណុចណាទេ និងបានចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។

**ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

ខ្ទប់ស៊ើបសួរ "...."

លេខស៊ើបសួរ ៖......./១៥.០៨.១៩

លេខ ជ.ព.ស

## ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

**យើង..................ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។**

**អមដោយលោក ...............ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ។**

-បានឃើញមាត្រា ២០៣, ២០៤, ២០៥ និងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ...........ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ........... អ.យ.... ចុះថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ......... ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ ឪពុកឈ្មោះ ......... "ស" ម្តាយឈ្មោះ ........"រ" ជាអនីតិជន ទោសគ្មានពីមុន។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច.........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ........... រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង។

-បានឃើញ កំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី ។

### I.ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១/ក្នុងករណីបច្ចុប្បន្នជនត្រូវចោទឈ្មោះ ............ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ត្រូវចោទពីបទ៖ **រំលោភលើទំនុកចិត្ត**

២/ប្រព្រឹត្តនៅ នៅចំណុច .........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់ .........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩

៣/ការពិភាក្សាដេញដោលចំពោះមុខត្រូវបានធ្វើឡើងតាមនីតិវិធីរួចរាល់ហើយ។

៤/តំណាងអយ្យការបានស្នើសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកលើសំអាងហេតុដូចតទៅ៖

☑ក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
☑ធានារក្សាជនត្រូវចោទទុកជូនតុលាការតាមនីតិវិធី

II. **សំអាងហេតុសេចក្តីសម្រេច**

១/ជនត្រូវចោទត្រូវចោទពីបទមជ្ឈិម ដែលច្បាប់តម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី១ឆ្នាំ ។

២/ជាផលវិបាកយល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានសារៈសំខាន់ដើម្បី៖

☐រារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
☑បង្កាបទល្មើសកុំឲ្យកើតមានជាថ្មី
☐រារាំងកុំឲ្យមានការគាមសង្កត់សាក្សី ឬជនរងគ្រោះ
☑ក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
☑ធានារក្សាជនត្រូវចោទទុកជូនតុលាការតាមនីតិវិធីដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានលក្ខណៈតឹងរ៉ឹងនិងមានប្រសិទ្ធិភាពអាចធានាឲ្យមានការបំពេញកិច្ចប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែកាឃុំ ខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ ។

**<u>សម្រេច</u>**

ឃុំខ្លួនជនត្រូវចោទឈ្មោះ.............. ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ជាបណ្តោះអាសន្នរយៈពេលអតិបរមា ។

ថ្ងៃ.................... ខែ....... ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី..... ខែ...... ឆ្នាំ២០២០
**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

**<u>លិខិតបញ្ជូន</u>**

យើង ...................បានជូនដំណឹងពីដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ..........ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ដល់ឈ្មោះខាងក្រោម៖

**អ្នកប្រគល់** **អ្នកទទួល**

**ក្រឡាបញ្ជី** ជនត្រូវចោទ

ភ្នំពេញ, ចុះថ្ងៃទី........ ខែ..... ឆ្នាំ២០១៩

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
បន្ទប់ស៊ើបសួរ "......"
លេខ៖ ................ "ច១"ដ.ឃ.ខ

# ដីកាបង្គាប់ឲ្យឃុំខ្លួន

**យើង..............ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។**

-បានឃើញមាត្រា ២០៦, ២១៥ ,២២០ ,២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ......... ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ .......ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ....... អ.យ.... ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ............... ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ ឪពុកឈ្មោះ ......... "ស" ម្ដាយឈ្មោះ ........"រ" ជាអនីតិជន ទោសគ្មានពីមុន។(ឃាត់ខ្លួន)

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច.........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ........... រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ........... "ច១" ជ.ព.ស ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## បង្គាប់

១/ឲ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទឈ្មោះ ............................ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទៅពន្ធនាគាររាជធានីភ្នំពេញ (PJ) ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ។

២/ឲ្យប្រធានពន្ធនាគាររាជធានីភ្នំពេញ (PJ) ទទួលយកជននេះ និងឃុំខ្លួនជននេះរហូតដល់មានបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

៣/ឲ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឲ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

ថ្ងៃ............... ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី..... ខែ..... ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

យើង..............................................................................ប្រធាន

ពន្ធនាគារ ឬមណ្ឌលឃុំខ្លួន នៃក្រសួងមហាផ្ទៃ ឃុំខ្លួនបានអនុវត្តឃុំខ្លួនឈ្មោះ
.......................................

ភេទ..............អាយុ............ឆ្នាំ សញ្ជាតិ...........តាមអំណាចដីកាបង្គាប់ឲ្យឃុំខ្លួននេះ
កាលពី

ថ្ងៃទី..............ខែ...........ឆ្នាំ............ត្រង់លេខខ្លួន..................... ។

<u>សម្គាល់ ៖</u>

ជននេះត្រូវបានឃុំខ្លួនផ្សេងទៀតពីបទ
....................................................... កាលពីថ្ងៃទី................ខែ..........ឆ្នាំ
...........................ត្រង់លេខខ្លួន.........................................
តាមអំណាចដីកាបង្គាប់ឲ្យឃុំខ្លួនលេខ...........................កាលពីថ្ងៃទី..........ខែ............ឆ្នាំ
.........។

ភ្នំពេញ, ថ្ងៃទី...............ខែ...............ឆ្នាំ............

**ប្រធានមណ្ឌលអប់រំកែប្រែ**

សាលាដំបូងរាជធានីភ្នំពេញ

ចៅក្រមស៊ើបសួរបន្ទប់ "ច១" ជាន់ទី៥

លេខ..........................."........" ព.ទ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ដីកាចាត់ឲ្យស៊ើបសួរជំនួស

យើង ...................... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ..........ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ........ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ....... .អ.យ..... ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## យល់ឃើញថា

១-**ឈ្មោះ សេង ហុង** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅទល់មុខផ្ទះរបស់ឈ្មោះ............ ។(គេចខ្លួន)

២-ម្ចាស់ហាងទូលបញ្ចាំ នៅម្តុំស្តុបទេពជន(គេចខ្លួន)

ដែលជាប់ពាក់ព័ន្ធពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅ នៅចំណុច .........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ..........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ ពុំទាន់មានសាវតារជាតិគ្រប់គ្រាន់នៅឡើយ ហើយដើម្បីធានាការស៊ើបសួរឲ្យប្រព្រឹត្តទៅត្រឹមត្រូវ តាមនីតិវិធី និងគតិច្បាប់ គប្បីធ្វើការស្រាវជ្រាវសាវតារជាតិលើ ១ឈ្មោះ សេង ហុង ភេទប្រុស អាយុ១៧(គេចខ្លួន) និង ២ម្ចាស់ហាងទទួលបញ្ចាំនៅម្តុំស្តុបទេពជន (គេចខ្លួន)។

## ហេតុដូច្នេះសម្រេច

-ប្រគល់សិទ្ធិជូន **លោក អធិការនគរបាលខណ្ឌ**........... ចាត់មន្ត្រីជំនាញ ចុះស្រាវជ្រាវសាវតារជាតិលើឈ្មោះ **សេង ហុង** ភេទប្រុស អាយុ១៧ឆ្នាំ(គេចខ្លួន) និងម្ចាស់ហាងទទួលការបញ្ចាំ នៅម្តុំស្តុបទេពជន(គេចខ្លួន) ដែលជាប់ពាក់ព័ន្ធ ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅ នៅចំណុច .........ផ្ទះលេខ.........ផ្លូវ.........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ ។

-ក្រោយពីបានស្រាវជ្រាវសាវតារជាតិរួចហើយ សូមលោកមេត្តាផ្ញើលទ្ធផល នៃការស្រាវជ្រាវមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចៅក្រមស៊ើបសួរ មានមូលដ្ឋានស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ បានទាន់ពេលវេលា ។

ថ្ងៃ.................ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី..... ខែ..... ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

ភ្ជាប់មកជាមួយនូវ

ដោយការណ៍សុំយោគលេខ២០៥០/២០ ជ.អ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ចៅក្រមស៊ើបសួរ "ច១"

លេខ................."ប៊១"ព្រ.ទ

## លិខិតជូនដំណឹង
## ស្តីពីការបិទបញ្ចប់ការស៊ើបសួរ

យើង.................. ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .......... ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **៣៨៧៣** អ.យ.ប ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ **៣៨៥៥** ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ ។

**<u>ជម្រាបមក</u>**

**តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ។

សូមលោក លោកស្រី មេត្តាជ្រាបថា ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ........ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ដែលមានជនត្រូវចោទ ១ឈ្មោះ............ភេទប្រុស អាយុ១៧ឆ្នាំ(ក្នុងឃុំ) ២ឈ្មោះសេង ហុង ភេទប្រុស អាយុ១៧ឆ្នាំ(គេចខ្លួន) ៣ ម្ចាស់ហាងទទួលបញ្ចាំនៅម៉ុស្តូបទេពផន (គេចខ្លួន)ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ រំលោភលើទំនុកចិត្ត និងទទួលផលចោរកម្ម ប្រព្រឹត្តនៅ នៅចំណុច .........ផ្ទះលេខ.........ផ្លូវ..........ក្រុម.........ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៩១,៣៩២និងមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

នោះយើងបានស៊ើបសួរចប់សព្វគ្រប់តាមនីតិវិធីហើយ ។

ហេតុដូច្នេះយើងសម្រេចបិទបញ្ចប់ការស៊ើបសួរ សូមលោក លោកស្រី មេត្តាជ្រាបជាដំណឹង ។

ថ្ងៃ.................ខែ........ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ..... ឆ្នាំ២០១៩

**ចៅក្រមស៊ើប**

យោបល់តំណាងអយ្យការ

**សួរ**................................................

..................................................

រាជធានីភ្នំពេញ ថ្ងៃទី .......ខែ.........ឆ្នាំ២០១៩

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ..........
ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩
ចៅក្រមស៊ើបសួរអង្គភាព .......
លេខ.................. ........ ជ.ជ

## ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង **ឡុង ចន្ថា** ជាចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សរុបលេខ០៤២/២០១៧ រ.ប.ក ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ....... អ.យ.... ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ របស់តំណាងអយ្យការ សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ........... អ.យ.ធ ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០២០ របស់តំណាងអយ្យការ សាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យស៊ើបសួរ ចប់សព្វគ្រប់ហើយ យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់ លើឈ្មោះ .....................ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរសិស្ស មានទីកន្លែងកំណើតនៅភូមិព្រៃឈរ ឃុំក្រូចឆ្មារ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ........ ភូមិ......... សង្កាត់..........ខណ្ឌ.........រាជធានីភ្នំពេញ ជានីតិជន ទោសពីមុន គ្មាន។

ពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុច.........ផ្ទះលេខ.........ផ្លូវ.........ក្រុម......... ភូមិ........សង្កាត់.........ខណ្ឌ...........រាជធានីភ្នំពេញ, កាលពីថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

### ហេតុដូច្នេះសម្រេច

-បញ្ជូនជនជាប់ចោទឈ្មោះ ................. ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ និងសំណុំរឿងព្រហ្មទណ្ឌលេខ.......... ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិន ក្នុងរឿងនេះ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ ។

-រក្សាទុកជនត្រូវចោទឈ្មោះ.......................... ឲ្យជាប់ឃុំបណ្តោះអាសន្ន ទុកជូនតុលាការជំនុំជម្រះតាមច្បាប់។

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី....ខែ...... ឆ្នាំ២០២០

**ក្រឡាបញ្ជី**

រាជធានីភ្នំពេញ ថ្ងៃទី....ខែ... ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

**ជ.ព្រះរាជអាជ្ញា**

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី... 

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

## មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

## មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

## មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤- អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សំដៅដល់អនីតិជន ដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- អ្នកទំនុកបម្រុង សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្ដី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្ដល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- របាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន សំដៅដល់របាយការណ៍ស្ដីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្ដល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្ដុះបណ្ដាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- មណ្ឌលយុវនីតិសម្បទា សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្ដល់សេវាការពារ ថែទាំ អប់រំ ស្ដារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

# ជំពូកទី ២
# គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

## មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណាពល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្ដីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្ដល់ឱកាសឲ្យអនីតិជនសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្ដីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែដោយការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣
# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវិជ្ជមានភាពរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែក្នុងករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

## មាត្រា ៨.- ការ ទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិវៈ កឋាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូ.របស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

## មាត្រា ៩.- ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

# ជំពូកទី ៤
# ជំនួយផ្នែកសេវាសង្គមកិច្ច

## មាត្រា ១០.- ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## មាត្រា ១១.- ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

- ប្រមូលព័ត៌មានស្ដីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ញាអារម្មណ៍ ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្ដល់របាយការណ៍ និងយោបល់ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម អយ្យការ និងតុលាការ
- ផ្ដល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី
- រៀបចំ និងផ្ដល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច
- ផ្ដល់សេវាស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន
- ភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

## ជំពូកទី ៥
## នគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

### មាត្រា ១២.- សមត្ថកិច្ចនគរបាលយុត្តិធម៌ក្នុងការពិនិត្យបទឧក្រិដ្ឋ និងបទមជ្ឈិម

នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង ។

នគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្ដីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឱ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

### មាត្រា ១៣.- អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យ និងដោះស្រាយបទលហុ

អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។

ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុ នគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ ។

ករណីដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នគរបាលយុត្តិធម៌ត្រូវធ្វើរបាយ-ការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នក តំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

**មាត្រា ១៤.- នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ**

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីមានវិវាទទាក់ទងនឹងអាយុរបស់អនីតិជននៅពេលប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាជាបន្ទាន់ ។

## មាត្រា ១៥.- ការចាប់ខ្លួន

នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខនិងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិធនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត ។

## មាត្រា ១៦.- ការឆែកឆេរលើខ្លួនបុគ្គល

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន ។ ការឆែកឆេរខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចចៀសវាងបាន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុនិងចុះនិទ្ទេសអំពីបញ្ហានេះ ។

## មាត្រា ១៧.- ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាបរុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ ។ ប៉ុន្តែ អនីតិជះដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតដែលអាចធ្វើទៅ

## មាត្រា ១៨.– ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ ។ ក្នុងករណីមិនអាចផ្ដល់ដំណឹងនេះជាបន្ទាន់ ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើ ទៅបាន អំពី ៖

- មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស
- ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ
- សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល ។

ក្នុងករណីមិនអាចទាក់ទងអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានការយល់ព្រមពីអនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមផងដែរទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្ដល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន ។ ក្នុងករណីដែលគ្មានការជ្រើសរើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែភាសាដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជននោះពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច និងស្វែងរកមេធាវីនិងអ្នកទំនុកបម្រុង ទោះបីជាការជូនដំណឹង ឬការព្យាយាមជូនដំណឹងនោះមិនបានទទួលលទ្ធផលក្ដី។

## មាត្រា ១៩.– ការពិនិត្យសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត

ក្នុងករណីអនីតិជនមានរបួស ឬមានបញ្ហាសុខភាពហើយត្រូវការការព្យាបាល នគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីធ្វើការពិនិត្យព្យាបាល ។

រាល់ការចំណាយលើការពិនិត្យនិងព្យាបាលជាបន្ទុករបស់រដ្ឋ ក្នុងករណីដែលឪពុកម្ដាយ ឬអ្នកអាណាព្យាបាលគ្មានលទ្ធភាព ។

កំណត់ហេតុ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខភាព ត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

## មាត្រា ២០.- កំណត់ហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន

ច្បាប់ចម្លងនៃកំណត់ហេតុស្តីពីការចាប់ខ្លួននិងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនត្រូវផ្តល់ឲ្យមេធាវីតាមការស្នើសុំ ។

នៅតាមអង្គភាពដែលមាននគរបាលយុត្តិធម៌នីមួយៗ ត្រូវមានបញ្ជីដោយឡែកស្តីពីការឃាត់ខ្លួនអនីតិជន ។

## មាត្រា ២១.- នីតិវិធីមុនការស្តាប់ចម្លើយ

អនីតិជនត្រូវទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជននិងជាសម្ងាត់ ប្រសិនបើមានការស្នើសុំ លើកលែងតែជនទាំងនេះមានការទាក់ទិនក្នុងរឿងជាមួយ ។ ការជួបសន្ទនាឬទាក់ទងគ្នាមានរយៈពេល ៣០ (សាមសិប) នាទី និងត្រូវធ្វើមុនពេលស្តាប់ចម្លើយ ប្រសិនបើអាចធ្វើទៅបាន ។

## មាត្រា ២២.- ការស្តាប់ចម្លើយ

មុនពេលផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានជាពិសេស គឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី ។

ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជននិងជាការសម្ងាត់ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចដែលមានសិទ្ធិ ហើយអាចផ្តល់ជំនួយដល់អនីតិជន មានសិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយអនីតិជនបាន ។

មន្ត្រីនគរបាលយុត្តិធម៌អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយ ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់មិនអាចចូលរួមបាន ត្រូវអនុញ្ញាតឲ្យអ្នកទំនុកបម្រុងអនីតិជនចូលរួមជំនួស ប្រសិនបើមាន ។

ក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬមេធាវីរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ចក្នុងពេលស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាននោះ ហើយបញ្ចូលក្នុងសំណុំរឿងរបស់អនីតិជន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានបាន មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអាន កំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ ។

អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុនោះ ដោយត្រូវចុះនិទ្ទេស ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៣.- ការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាផ្សព្វផ្សាយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ក្នុងករណីអនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតស្រាមដៃ ។

អនីតិជនដែលត្រូវឃាត់ខ្លួន ត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ ។

អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៦
# ការចោទប្រកាន់

## មាត្រា ២៤.– សមត្ថកិច្ចរបស់អង្គការអយ្យការ

បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន ។

ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្ដីអនីតិជន ទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាតឬមិនដាច់ខាតក្ដី ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្ដីអនីតិជន ត្រូវទទួលបានការបណ្ដុះបណ្ដាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន ។

## មាត្រា ២៥.– ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

ព្រះរាជអាជ្ញាត្រូវពិនិត្យសំណុំឯកសារ និងពាក្យប្ដឹងដែលខ្លួនបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ។

ក្នុងករណីមានមន្ទិលសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។

ក្នុងករណីការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋានអំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ ។

## មាត្រា ២៦.– ការស្ដាប់ចម្លើយ

ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្ដាប់ចម្លើយអំពីសិទ្ធិដែលមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ដោយប្រើភាសានិងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុនពេលធ្វើការស្ដាប់ចម្លើយ ។ ក្នុងករណីដែលគ្មានការជ្រើសរើសព្រះរាជអាជ្ញាត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះ ។

ការស្ដាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្ដាប់ចម្លើយនេះត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្ដាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ក្នុងករណីអវត្តមានជនណាមួយខាងលើ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុ ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន ។

មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខាឬផ្តិតម្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្តិតម្រាមដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៧.- ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្រោយពីបានទទួលអនីតិជនពីព្រះរាជអាជ្ញាហើយ ប្រសិនបើមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត យល់ឃើញថាអនីតិជននោះចាំបាច់ត្រូវមានកិច្ចការពារនិងថែទាំ នោះមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បាន

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការជូនដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយប្រយោជន៍អនីតិជន ។

### មាត្រា ៣០.- ការបំបែកសំណុំរឿង

ប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថា អំពើប្រព្រឹត្តនោះមានសហចារី អ្នកផ្ដើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឲ្យដាច់ដោយឡែកពីគ្នា ។

## ជំពូកទី ៧
## ការស៊ើបសួរ

### មាត្រា ៣១.- សមត្ថកិច្ចនៃការស៊ើបសួរ

ការស៊ើបសួរករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន ។

### មាត្រា ៣២.- ការបើកការស៊ើបសួរ

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ។

ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្ដាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ។

### មាត្រា ៣៣.- ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ៣៤.- ការផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជន

ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។

## មាត្រា ៣៥.- ការស្តាប់ចម្លើយអនីតិជន

ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច ។

ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។

ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឱ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ ។

ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឱ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានការស្នើសុំ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ៣៦.- ការលើកពេលស្តាប់ចម្លើយ

ក្នុងករណីអវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃការបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

វត្តមាន ឬអវត្តមានរបស់មេធាវី មិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬបន្តឃុំខ្លួនបណ្តោះអាសន្នឡើយ ។

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជក អាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្ដីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណីតុលាការសម្រេចសេចក្ដីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន ជាវិធានការចុងក្រោយ ។

បន្ថែមលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ ប្រសិនបើមាន ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ៤០.- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប ។

## មាត្រា ៤១.– ការដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ។ ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជនអាចសុំឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។

## មាត្រា ៤២.– ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពីការវាយតម្លៃប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ ក្នុងករណីរបាយការណ៍

ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលខ្លី បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់ចែងការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់ចែងការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលខ្ទួទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ៤៣.- ការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្វែររបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជន ។

# ជំពូកទី ៨
# សមត្ថកិច្ចរបស់សាលាដំបូង

## មាត្រា ៤៤.- សមត្ថកិច្ចនៃការជំនុំជម្រះ

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន ជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។

សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទលហុ ។

## មាត្រា ៤៥.- អាទិភាពលើរឿងក្តីអនីតិជន

តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ករណីដែលរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

## មាត្រា ៤៦.- នីតិវិធីមុនពេលសវនាការ

មុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ។

ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះ តាមតម្រូវការ ។

## មាត្រា ៤៧.- សវនាការជាអសាធារណៈ

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ។

មានតែបុគ្គលដែលមានសិទ្ធិ ភារកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន ។

## មាត្រា ៤៨.- សវនាការ

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី ។

ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ ។

## មាត្រា ៤៩.- ការរួចផុតពីបទចោទ

ក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីតុលាការរកឃើញថាអនីតិជនខាងលើពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលខ្វះទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ៥០.- ជំនួយរបស់មេធាវី

ជំនួយរបស់មេធាវីត្រូវតែមានជាចំាបាច់នៅក្នុងសវនាការ ។ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ ។

តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឲ្យមេធាវីសម្រាប់រៀបចំការពារក្តី ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន ។

## មាត្រា ៥១.- ការផ្ដល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជន

នៅពេលចាប់ផ្ដើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម ៖

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្ដី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្ដឹងជំទាស់ទៅក្រុមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្ដឹងឧទ្ធរណ៍ ។

## មាត្រា ៥២.- អំណាចរបស់តុលាការក្នុងការបង្វែរ

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។

ក្នុងករណីលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ តុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិនបន្ទាប់មកត្រូវ ៖

- ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការបង្វែរ
- ឲ្យអនីតិជនចុះហត្ថលេខា ឬផ្ដិតម្រាមដៃអនុវត្តផែនការបង្វែរ ។

ក្នុងករណីតុលាការសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០(ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្ដឹងសុំ ។

ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះ ទៅមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់ចែងការសម្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នេះមន្ទីរ ឬការិយាល័យត្រូវចាត់ចែងការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។

ក្នុងករណីការអនុវត្តផែនការបង្វែរទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់ចែងការតាមនីតិវិធី ។

## មាត្រា ៥៣.- ចម្លើយសារភាពនៅពេលសវនាការ

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែងការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាង នៃពិរុទ្ធភាពឡើយ ។

ការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។

ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស ។

## មាត្រា ៥៤.- ការប្រកាសសាលក្រម

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ។

ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅ

សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។

## ជំពូកទី ៩
## សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់

### មាត្រា ៥៥.- សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប ។

### មាត្រា ៥៦.- ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

ក្នុងករណីមានបណ្តឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅតុលាការកំពូល ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្តឹងសាទុក្ខ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។

### មាត្រា ៥៧.- អាទិភាពនៃរឿងក្តីអនីតិជន

សាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការ ជំនុំជម្រះជាអាទិភាព ពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំ ។ ចំពោះរឿងក្តីដែលអនីតិជនជាប់ឃុំ ត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែ យ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសក្យានុម័តដែលមិនអាចជម្នះបាន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ក្នុងករណីរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

### មាត្រា ៥៨.- អំណាចរបស់សាលាឧទ្ធរណ៍ក្នុងការបង្វែរ

បទប្បញ្ញត្តិនៃមាត្រា ៥២ (អំណាចរបស់តុលាការក្នុងការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះអំណាចក្នុងការបង្វែររបស់សាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

### មាត្រា ៥៩.- ការពន្យារតម្រិធានដល់តុលាការជាន់ខ្ពស់

វិធានដែលត្រូវអនុវត្តចំពោះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះមានភាពផ្ទុយពីលក្ខណៈនៃវិធានដែលអនុវត្តនៅតុលាការជាន់ខ្ពស់ ។

## ជំពូកទី ១០
## ការបង្វែរ

### មាត្រា ៦០.- ការបង្វែរ

ការបង្វែរជាវិធានដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗ នៃនីតិវិធីតុលាការ ។

### មាត្រា ៦១.- អាជ្ញាធរទទួលបន្ទុកបង្វែរ

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ។

### មាត្រា ៦២.- គោលបំណងនៃការបង្វែរ

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជំរុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្ដីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធអាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងចៀសវាងការប្រព្រឹត្តបទល្មើសសាជាថ្មី
- បង្ការការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស ។

## មាត្រា ៦៣.- លក្ខខណ្ឌអប្បបរមានៃការបង្វែរ

ការបង្វែរ ត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

ក- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។

ខ- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ ។

គ- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ។

ឃ- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តជានបង្វែរ ។

## មាត្រា ៦៤.- លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ

ក្នុងករណីរឿងក្ដីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់នេះ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

ក- កាលៈទេសៈនៃបទល្មើស ។

ខ- ស្ថានភាពនៃបទល្មើស ។

គ- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត ។

ឃ- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។

ង- ព្យសនកម្មរបស់ជនរងគ្រោះ ។

ច- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម ។

## មាត្រា ៦៥.- វិធានការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ
- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងចីរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើសសាជាថ្មី
- ឱ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្ដីពីការងារ និងអនុសញ្ញាអន្តរជាតិស្ដីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

## មាត្រា ៦៦.- ការរៀបចំបង្កើតផែនការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្វែរ ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

ក្នុងការបង្កើតផែនការបង្វែរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ ៖

- ផ្ដល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឱ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត

- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ជៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្ដាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

## មាត្រា ៦៧.– និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ

ផែនការបង្វែរត្រូវមាននិទ្ទេសដូចខាងក្រោម ៖
- វិធានការបង្វែរណាមួយដូចមានចែងក្នុងមាត្រា ៦៥ (វិធានការបង្វែរ) នៃច្បាប់នេះ និងរយៈពេលនៃការអនុវត្តវិធានការបង្វែរ
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្ដល់ឲ្យអនីតិជន
- បញ្ជាក់ឲ្យច្បាស់ពីបុគ្គល ឬអង្គការដែលផ្ដល់សេវា និងជំនួយទាំងនោះ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់ខ្លួនរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ពីអាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ ។ អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជានគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យតាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ ។

ផែនការបង្វែរត្រូវចុះ ៖
- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន
- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលពាក់ព័ន្ធ ។

ច្បាប់ចម្លងនៃផែនការបង្វែរត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ។

## មាត្រា ៦៨.- ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ

ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនយល់ស្រប ចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ (មួយ) ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

## មាត្រា ៦៩.- ការអនុវត្តផែនការបង្វែរ

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវជានាប់ប៉ាងអនុវត្តសេចក្ដីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្ដីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

## មាត្រា ៧០.- ការកែប្រែវិធានការបង្វែរ

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្ដែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។

អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

## មាត្រា ៧១.- បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ ។

ភ្នាក់ងារសង្គមកិច្ចត្រូវផ្ដល់របាយការណ៍ស្ដីពី លទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងផែនការបង្វែរ ឬនៅក្នុងផែនការបង្វែរដែលត្រូវបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ។

ក្រោយពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ និងមេធាវីរបស់អនីតិជន ប្រសិនបើមាន ឲ្យចូលមកបង្ហាញខ្លួនក្នុងរយៈពេល មិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមផែនការបង្វែរ ។

ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រា ៦៦ (ការរៀបចំបង្កើតផែនការបង្វែរ) ដល់ មាត្រា ៧០ (ការកែប្រែផែនការបង្វែរ) ខាងលើនេះ ត្រូវយកមកអនុវត្តក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្វែរចេញដីកាបង្វែរថ្មី ។

ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបន្តចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១១
## ការដោះលែងដោយមានលក្ខខណ្ឌ

### មាត្រា ៧២.- ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្ដល់ឲ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ ១ (មួយ) ឆ្នាំ
- ចំនួនពាក់កណ្ដាលនៃទោស ក្នុងករណីផ្សេងទៀត ។

### មាត្រា ៧៣.- បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ៖

- ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា

- ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជននោះ
- បេសកកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស ។

## ជំពូកទី ១២
## ការផ្ដល់ និងការមាននីតិសម្បទាឡើងវិញ

### មាត្រា ៧៤.- លក្ខខណ្ឌលើរយៈពេលដាក់ទទនឹងពាក្យសុំឲ្យមានការផ្ដល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្ដើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

ពាក្យសុំអាចត្រូវធ្វើឡើងដោយ ៖

- ទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន ។

### មាត្រា ៧៥.- ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល ៖

- ៣ (បី)ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ១ (មួយ)ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី)ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្ដើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១៣
## ការបង្កើត និងសមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

### មាត្រា ៧៦.- ការបង្កើតមណ្ឌលយុវនីតិសម្បទា

ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន ។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៧៧.- ការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ៧៨.- បញ្ជីឈ្មោះអនីតិជន

គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព ។

បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

# ជំពូកទី ១៤
## វិធានការទាក់ទងនឹងការឃុំខ្លួនអនីតិជន

### មាត្រា ៧៩.- គោលបំណងនៃការឃុំខ្លួន

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទា ជាអាទិ៍ ការបណ្តុះបណ្តាលការអប់រំ ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។

មន្ត្រីមណ្ឌលឃុំនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

## មាត្រា ៨០.‒ សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ថាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឱ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយកំណឹអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឱ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។

## មាត្រា ៨១.‒ សេវាសម្រាប់អនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចខាងក្រោមនេះ ៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង ។

## មាត្រា ៨២.– ការរក្សាអនីតិជន

ត្រូវរក្សាអនីតិជននៅក្នុងមណ្ឌលឃុំនីតិសម្បទាដូចខាងក្រោមនេះ ៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។ អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា
- នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជំងឺឆ្លង ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន ។

របៀបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ៨៣.– ចំណាត់ថ្នាក់សន្តិសុខនៅក្នុងមណ្ឌលឃុំនីតិសម្បទា

ចំណាត់ថ្នាក់សន្តិសុខសម្រាប់អនីតិជននៅក្នុងមណ្ឌលឃុំនីតិសម្បទា ត្រូវស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុត និងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ៨៤.- ភ្នាក់ងារក្នុងមណ្ឌលយុវនីតិសម្បទា

ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ជាអាទិ៍ មន្ត្រីមណ្ឌលយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច អ្នកជំនាញផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះបណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

មន្ត្រី ឬបុគ្គលិកមណ្ឌលយុវនីតិសម្បទា មិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឲ្យដាក់វិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសខ្លួនឡើយ ។

## មាត្រា ៨៥.- ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលយុវនីតិសម្បទា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។

យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលយុវនីតិសម្បទានានាបានគ្រប់ពេលវេលា ។

# ជំពូកទី ១៥
# អន្តរប្បញ្ញត្តិ

## មាត្រា ៨៦.- បទប្បញ្ញត្តិទាក់ទងនឹងចៅក្រម

ចៅក្រមអយ្យការ និងចៅក្រមដែលត្រូវបានចាត់ឲ្យទទួលបន្ទុកលើរឿងក្តីអនីតិជនតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់ពេលមានចៅក្រមជំនាញទាក់ទងនឹងអនីតិជន ។

## មាត្រា ៨៧.- នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន

នគរបាលយុត្តិធម៌ដែលកំពុងចាត់ការលើរឿងក្តីអនីតិជនតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់ពេលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៨៨.- មណ្ឌលយុវនីតិសម្បទា**

ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា ។

បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៦

## អវសានប្បញ្ញត្តិ

**មាត្រា ៨៩.- ការអនុវត្តច្បាប់នេះ**

ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល ៦ (ប្រាំមួយ) ខែ ទើបអនុវត្ត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស.រកម.០៧១៦.០១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ហត្ថលេខា**

**វង សូត**

លេខ: ៧៦៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

ភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥

**លេខ:** ០១.កយ.សរាចរ.២០០៥

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### សូមជំរាបមក

- ប្រធានតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ប្រធានសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ប្រធានតុលាការខេត្ត-ក្រុង
- ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
- ប្រធានតុលាការយោធា
- ព្រះរាជអាជ្ញាអមតុលាការយោធា
- មន្ត្រីនគរបាលយុត្តិធម៌

<u>សូមជ្រាប</u>។

<u>កម្មវត្ថុ</u>: - សេចក្តីណែនាំអំពីការអនុវត្តន៍គោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមាន ទាក់ទងនឹងយុត្តិធម៌អនីតិជន។

<u>យោង</u>: - រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ
- ច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីព្រហ្មទណ្ឌ

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល
- ច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន
- ច្បាប់ស្តីពីរបបសារពត៌មាន

កន្លងមក ក្រសួងយុត្តិធម៌ បានកត់សំគាល់ឃើញថា មានបទល្មើសជាច្រើនបានកើនឡើង ដែលប្រព្រឹត្តដោយអនីតិជន ប៉ុន្តែយើងពុំទាន់បានអនុវត្តច្បាប់ ទៅលើអនីតិជនទាំងនោះបានល្អនៅឡើយ ទោះបីមានគោលការណ៍ច្បាប់ បទបញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិមួយចំនួនកំពុងនៅជាធរមាន ដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើងបាន ទទួលស្គាល់រួចមកហើយនោះក៏ដោយ ក៏យើងមិនទាន់បានលើកយកមកអនុវត្តឱ្យបានពេញលេញនៅឡើយទេ។ ដូច្នេះ ក្រសួងយុត្តិធម៌ សូមលើកយកគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ ដែលមានចែងទាក់ទងនឹងអនីតិជន តាមលំដាប់ លំដោយ ដូចខាងក្រោមនេះ ដើម្បីធ្វើការណែនាំ ក្នុងការអនុវត្តន៍ច្បាប់ ទៅលើអនីតិជនឱ្យមានប្រសិទ្ធិភាពខ្ពស់តទៅៈ-

# គោលការណ៍ស្តីពី យុត្តិធម៌អនីតិជន

## ក ~ ដំណាក់កាលនៃនគរបាលយុត្តិធម៌

១. ការចាប់ខ្លួន និងការឃាត់ខ្លួនអនីតិជន គួរអនុវត្តសំរាប់តែវិធានការចុងក្រោយបំផុតប៉ុណ្ណោះ។ ការចាប់ខ្លួនត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់ ទោះជាការចាប់ខ្លួននោះធ្វើឡើងតាមរយៈដីកាចាប់ខ្លួនក្តី តាមរយៈភស្តុតាងស៊ីសង្វាក់ក្តី និងតាមរយៈបទល្មើសជាក់ស្តែងក្តី ។

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- ច្បាប់ស្តីពីនីតិព្រហ្មទណ្ឌ មាត្រា ៣៥- ៣៨ (វិសោធនកម្ម) មាត្រា ៤៧
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៨- ១៩
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៩
- សិទ្ធិនយោបាយ មាត្រា ៩.១
- សិទ្ធិកុមារ មាត្រា ៣៧ (ខ)
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ១៣

- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ២
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ២- ៣៦
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣ ដល់ ៦ និង ៣ ដល់ ១១

២. ការអនុវត្តចាប់ខ្លួនអនីតិជន អាចប្រើប្រាស់កំលាំងបានតែចំនួនអប្បបរិមាចាំបាច់ប៉ុណ្ណោះ ។

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១២
- សិទ្ធិកុមារ មាត្រា ៣៧
- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ៦៣
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣ ដល់ ៩

៣. ការចាប់ខ្លួនអនីតិជន ត្រូវចៀសវាងនូវការធ្វើឱ្យអាម៉ាស់មុខ និងការប្រមាថដល់កុមារ ។

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១២
- សិទ្ធិនយោបាយ មាត្រា ១០.១
- សិទ្ធិកុមារ មាត្រា ៣៧(គ)
- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ១២ - ៦៣
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣ ដល់៩ និង ៣ - ៦២

៤. នៅពេលអនុវត្តការចាប់ខ្លួនកុមារ នគរបាលយុត្តិធម៌ត្រូវប្រាប់ទៅកុមារ អំពីមូលហេតុនៃការចាប់ខ្លួន និងបទចោទប្រកាន់ ។

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១២ - ១៨ - ១៩
- សិទ្ធិនយោបាយ មាត្រា ៩.២
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)

- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ៧
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១០ - ១១
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣ ដល់ ៩ និង ៣ ដល់ ១០ និង៣ ដល់ ១១ និង ៣ ដល់ ១៥

៥. នៅពេលអនុវត្តការចាប់ខ្លួនកុមារ នគរបាលយុត្តិធម៌ ត្រូវប្រាប់អំពីសិទ្ធិនានារបស់កុមារដល់កុមារ ដែលត្រូវចាប់ខ្លួននោះ រួមមាន:-

- សិទ្ធិបដិសេធមិនទាន់ឆ្លើយ ដោយរង់ចាំមានមេធាវីការពារខ្លួនតាមផ្លូវច្បាប់
- សិទ្ធិធានាដើម្បីកុំឱ្យធ្វើពិរុទ្ធកម្មខ្លួនឯង
- សិទ្ធិទំនាក់ទំនងជាមួយមិត្តភ័ក្តិ ឬសាច់ញាតិ ដើម្បីជូនដំណឹងពីទីកន្លែងឃាត់ខ្លួន
- សិទ្ធិរបស់ជនជាតិបរទេសក្នុងការទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុលរបស់ខ្លួន
- សិទ្ធិរកអ្នកបកប្រែភាសា

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- សិទ្ធិនយោបាយ មាត្រា ១៤
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣).(៤).(៦)
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ៧
- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ៤
- វិធានអប្បបរិមារបស់អង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងអ្នកទោស វិធាន ៣៨
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១៣ - ១៤
- អនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងកុងស៊ុល មាត្រា ៣៦
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ២.៤៣ - ៣.៩ - ៣.១៥ - ៣.២៥

៦. កុមារត្រូវទទួលបានមេធាវីយ៉ាងឆាប់បំផុត។ ប្រសិនបើកុមារមិនទាន់មានមេធាវី នគរបាលយុត្តិធម៌ ត្រូវប្រាប់អំពី សិទ្ធិដែលត្រូវមានមេធាវី។

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១០
- សិទ្ធិនយោបាយ មាត្រា ១៤
- សិទ្ធិកុមារ មាត្រា ៣៧(ឃ) - ៤០.២ (ខ)២
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ៧
- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ១៨
- វិធានអប្បបរិមារបស់អង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងអ្នកទោស វិធាន ៩៣
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១១ - ១៧ - ១៨
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣.៦២

៧. ក្រោយពេលអនុវត្តការចាប់ខ្លួនកុមារ នគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ឪពុកម្តាយ អាណាព្យាបាល សមាជិកគ្រួសារ សាច់ញាតិរបស់កុមារ ឬនីតិជនទទួលខុសត្រូវដ៏ទៃទៀតអំពី ការចាប់ខ្លួន មូលហេតុនៃការចាប់ខ្លួន និង បទចោទប្រកាន់ទៅលើកុមារ។

- សិទ្ធិកុមារ មាត្រា ៤០.២ (ខ)២
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ៧ - ១០ - ១០.១
- វិធានអប្បបរិមារបស់អង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងអ្នកទោស វិធាន ៩២
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១១ - ១៦
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣.១៦

៨. នៅពេលអនុវត្តចាប់ខ្លួនកុមារ នគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុ ដោយបញ្ជាក់អំពី មូលហេតុនៃ ការចាប់ខ្លួន ពេលវេលាចាប់ខ្លួន អត្តសញ្ញាណរបស់នគរបាលយុត្តិធម៌ ឬមន្ត្រីអនុវត្តច្បាប់ដ៏ទៃទៀត ដែលចូលរួម ក្នុងការចាប់ខ្លួន ទីកន្លែងឃាត់ខ្លួន និងពេលវេលាដែលមកដល់កន្លែងឃាត់ខ្លួន។

- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន១៩-២០-២១
- វិធានអប្បបរិមារបស់អង្គការសហប្រជាជាតិស្តីពីការគ្រប់គ្រងអ្នកទោស វិធាន ៧
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១២
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣.១១

៩. កំណត់ហេតុសម្ភាសន៍ ឬកំណត់ហេតុសួរចម្លើយ នគរបាលយុត្តិធម៌ ត្រូវរក្សាទុកជាឯកសារសម្ងាត់។ ឪពុកម្ដាយ អាណាព្យាបាល ឬនីតិជនទទួលខុសត្រូវដទៃទៀត ត្រូវមានវត្តមានក្នុងពេលធ្វើសម្ភាសន៍។ អនីតិជន ត្រូវទទួលបានឱកាសទំនាក់ទំនងជាមួយ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកទទួលខុសត្រូវដទៃទៀត មុនពេលជួបសម្ភាសន៍។ នៅពេលបញ្ចប់កិច្ចសម្ភាសន៍ កំណត់ហេតុសម្ភាសន៍ ត្រូវអានឱ្យអនីតិជនស្ដាប់រួចឱ្យផ្ដិតមេដៃ។

- សិទ្ធិកុមារ មាត្រា ៤០.២ (ខ)៣
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ៧
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ២ ដល់ ៤៣ និង ៣ ដល់ ១៥

១០. នគរបាលយុត្តិធម៌ មិនត្រូវអនុញ្ញាតិឱ្យមានការផ្សព្វផ្សាយរឿងក្ដីអនីតិជន ដោយគ្មានច្បាប់អនុញ្ញាតិឡើយ។

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- ច្បាប់សារពត៌មាន មាត្រា ៤ - ៥- ១៥
- សិទ្ធិនយោបាយ មាត្រា ១៤.១
- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស មាត្រា ១២
- សិទ្ធិកុមារ មាត្រា ១៦ - ៤០.២ (ខ)(៣)
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ៨
- វិធានរបស់អង្គការសហប្រជាជាតិស្ដីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ១៩

១១. អនីតិជនត្រូវទទួលការឃុំខ្លួនដាច់ដោយឡែកពីនីតិជន និងដោយឡែកពីអនីតិជនដែលមានភេទផ្ទុយគ្នា។

- សិទ្ធិនយោបាយ មាត្រា ១០
- សិទ្ធិកុមារ មាត្រា ៣៧ (គ)
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ១៣.៤ - ២៦
- វិធានអប្បបរិមារបស់អង្គការសហប្រជាជាតិស្ដីពីការគ្រប់គ្រងអ្នកទោស វិធាន ៨- ៨៥
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣ ដល់ ១៥

១៥. កុមារដែលត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនទៅចៅក្រមជាបន្ទាន់។ ការឃុំខ្លួនអនីតិជន ត្រូវកំណត់ ទៅតាមរយៈពេលដែលបានកំណត់ដោយច្បាប់។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨ (វិសោធនីកម្ម) មាត្រា ៤៧
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៣
- សិទ្ធិនយោបាយ មាត្រា ៩.៣ - ១០.២ (ខ)
- សិទ្ធិកុមារ មាត្រា ៣៧ (ខ) - ៣៧ (ឃ) - ៤០.២(ខ)(៣)
- វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនប៉េកាំង វិធាន ១០.២
- វិធានរបស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវគេដកហូតសេរីភាព វិធាន ១៧
- គោលការណ៍ការពារចំពោះជនដែលស្ថិតក្នុងការឃុំខ្លួន ឬជាប់ពន្ធនាគារ គោលការណ៍ ១១- ៣៧- ៣៨
- ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌ ទំព័រ ៣ ដល់ ៩ និង ៣-១០

## ខ ~ ជំណាក់កាលនៅអយ្យការ

១- នៅពេលទទួលបានតែសំណុំរឿងពីនគរបាលយុត្តិធម៌ ប៉ុន្តែគ្មានជនជាប់សង្ស័យមកជាមួយនោះ ព្រះរាជអាជ្ញា គប្បីឱ្យដំណឹងដល់ឪពុកម្តាយ អាណាព្យាបាល របស់អនីតិជនដែលជាប់សង្ស័យអំពី បទចោទប្រកាន់ផ្សេងៗ ក្រោយពីចុះបញ្ជីសំណុំរឿងក្តីរួច។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)

២- ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតបឋមបន្ថែម ដើម្បីស្វែងរកការពិតនៃអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ។

ក- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមរបស់ព្រះរាជអាជ្ញាបានបង្ហាញឱ្យឃើញថា អាយុអនីតិជនដែលជាជនជាប់សង្ស័យនោះ តិចជាង ១៣ ឆ្នាំ ព្រះរាជអាជ្ញាគប្បីចេញដីកាតំកល់រឿងទុកឥតចាត់ការ ហើយឱ្យដំណឹងទៅភាគដើមបណ្តឹងរដ្ឋប្បវេណី។

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤.៥
- រដ្ឋធម្មនុញ្ញ មាត្រា ៣៨

ខ- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមរបស់ព្រះរាជអាជ្ញាបានបង្ហាញឱ្យឃើញថា អាយុអនីតិជនដែលជាជនជាប់សង្ស័យនោះ ចាប់ពី ១៣ ឆ្នាំឡើង ប៉ុន្តែតិចជាង ១៨ ឆ្នាំនោះ ព្រះរាជអាជ្ញាអា[illegible]ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការអង្កេតស៊ើបសួរបាន ។

គ- ប្រសិនបើការស៊ើបអង្កេតបឋមរបស់ព្រះរាជអាជ្ញាមិនអាចរកឃើញនូវអាយុពិតប្រា[illegible]របស់អនីតិជនដែលជាជនជាប់សង្ស័យនោះទេ នោះព្រះរាជអាជ្ញាត្រូវធ្វើដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ទៅចៅក្រមស៊ើបអង្កេតដើម្បីអង្កេតស៊ើបសួរស្វែងរកអាយុពិតប្រាកដ ។

- សិទ្ធិកុមារ មាត្រា ៤០.៣ (ក)

៣- មុនពេលធ្វើការសាកសួរ(សម្ភាសន៍)អនីតិជន ព្រះរាជអាជ្ញា គប្បីខិតខំស្វែងរកមេធាវីឱ្យជនជាប់សង្ស័យជាអនីតិជនឱ្យអស់លទ្ធភាពរបស់ខ្លួន។ ប្រសិនបើជនជាប់សង្ស័យជាអនីតិជនគ្មានលទ្ធភាពរកមេធាវីខ្លួនឯងបាន ព្រះរាជអាជ្ញាគប្បីរកមេធាវីដែលបំរើសេវាដោយមិនយកកំរៃឱ្យពួកគេតាមច្បាប់កំណត់ ។

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១០
- សិទ្ធិកុមារ មាត្រា ៤០.(ខ)(២)

៤- មុនពេលធ្វើការសាកសួរ(សម្ភាសន៍)អនីតិជន ជាដំបូងព្រះរាជអាជ្ញា គប្បីធ្វើការជូនដំណឹងទៅ ឪពុកម្តាយអាណាព្យាបាលរបស់ អនីតិជននោះ ជាមុនសិន ដើម្បីឱ្យពួកគេអាចចូលរួមក្នុងដំណើការសាកសួរ (សម្ភាសន៍) នេះ។ ប្រសិនបើឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជនដែលជាជនជាប់សង្ស័យ មិនបានទទួលដំណឹងដែលព្រះរាជអាជ្ញាបានជូនរួចហើយ ឬមិនអាចចូលរួមក្នុងដំណើរការសាកសួរបានទេនោះ ដំណើរការសាកសួរនៅតែបន្តដោយគ្មានការពន្យារពេលឡើយ ។

- សិទ្ធិកុមារ មាត្រា ៣.២ - ៤០.២ (ខ)(៣)

៥- ការសាកសួរ(សំភាសន៍)អនីតិជន ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា រួមជាមួយមេធាវី បើសិន ជាមានហើយក្នុងលក្ខណៈសំងាត់បំផុត ។

- សិទ្ធិកុមារ មាត្រា ៤០.២ខ៧

៦- បន្ទាប់ពីការសាកសួរ(សំភាសន៍)ចប់ភ្លាម កំណត់ហេតុសាកសួរ(សំភាសន៍)ត្រូវអានឱ្យអនីតិជននោះស្តាប់ឡើងវិញ ហើយឱ្យផ្តិតមេដៃ។ ប្រសិនបើមានវត្តមានឪពុកម្តាយ អាណាព្យាបាល និងមេធាវី ព្រះរាជអាជ្ញាគប្បីឱ្យឪពុកម្តាយ អាណាព្យាបាល និងមេធាវីរបស់អនីតិជននោះចូលរួមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុសាកសួរ(សម្ភាសន៍) នោះផងដែរ ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

៧-ព្រះរាជអាជ្ញាមិនអាចអនុញ្ញាតឱ្យមានការចុះផ្សាយចំពោះករណីអនីតិជនដោយគ្មានច្បាប់អនុញ្ញាតឡើយ ។

- ច្បាប់សារពត៌មាន មាត្រា ៤ - ៥ - ១៥
- សិទ្ធិកុមារ មាត្រា ១៦- ៤០.២(ខ)(៧)
- សិទ្ធិនយោបាយ មាត្រា ១៤.១

៨-ប្រសិនបើ ព្រះរាជអាជ្ញាសំរេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ផ្តើមចោទប្រកាន់) ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងអំពីបទចោទប្រកាន់ ទៅអនីតិជនដែលជាជនជាប់សង្ស័យ ឪពុកម្តាយ អាណាព្យាបាល របស់អនីតិជន ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)

៩- ក្នុងករណីដែលអនីតិជនរត់គេចខ្លួន ឬគ្មានខ្លួន ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជននោះ អំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)

១០-ក្នុងករណីមានខ្លួនអនីតិជនដែលជាជនជាប់សង្ស័យ នៅពេលធ្វើការផ្តើមចោទប្រកាន់រួច ព្រះរាជអាជ្ញាត្រូវបញ្ជូនខ្លួនជនជាប់សង្ស័យទៅ ចៅក្រមស៊ើបអង្កេតភ្លាម ។

- ច្បាប់ស្តីពីវិសោធនកម្មនៃនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៣
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

២- នៅពេលដែលជនជាប់សង្ស័យជាអនីតិជន បង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបអង្កេត ត្រូវប្រាប់ដោយផ្ទាល់ទៅអនីតិជន ឬតាមរយៈឪពុកម្តាយ អាណាព្យាបាល អំពីសិទ្ធិរបស់គេ។

សិទ្ធិទាំងឡាយដែលចៅក្រមស៊ើបអង្កេតត្រូវប្រាប់នោះ មានជាអាទិ៍:-

ក- សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)

ខ- សិទ្ធិទទួលបានជាជនឥតទោសរហូតដល់តុលាការសំរេចសេចក្តីជាស្ថាពរ
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៥
- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(១)
- សិទ្ធិនយោបាយ មាត្រា ១៤.២
- សេចក្តីប្រកាសជាសាកលសិទ្ធិមនុស្ស មាត្រា ១១

គ- សិទ្ធិមានមេធាវី
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៥ - ៧៦
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១០
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)
- សិទ្ធិនយោបាយ មាត្រា ១៤.៣(ឃ)

ឃ- សិទ្ធិមិនទាន់ឆ្លើយដោយគ្មានមេធាវី
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៥
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៤)

ង- សិទ្ធិចូលរួមរបស់ឪពុកម្ដាយ អាណាព្យាបាល ក្នុងដំណើរការរឿងក្ដី ប្រសិនបើមិនផ្ទុយនឹងផលប្រយោជន៍របស់កុមារ

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

ច- សិទ្ធិមានអ្នកបកប្រែភាសា ប្រសិនបើចាំបាច់

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៦)
- សិទ្ធិនយោបាយ មាត្រា ១៤.៣(ច)

ឆ- សិទ្ធិបដិសេធនូវការបង្ខិតបង្ខំឱ្យផ្ដល់សក្ខីកម្ម ឬសារភាពកំហុសដែលមិនត្រឹមត្រូវ

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៤)
- សិទ្ធិនយោបាយ ១៤.៣ឆ - នីតិវិធីព្រ ៧៥)

ជ- សិទ្ធិបង្ហាញសាក្សី និង បង្ហាញភស្តុតាង

- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨១
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៤.៤
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)
- សិទ្ធិនយោបាយ មាត្រា ១៤.៣(ង)

ឈ- សិទ្ធិជៀសផុតពី ទារុណកម្ម អំពើហឹង្សា ឬការគំរាមកំហែងផ្សេងៗ

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មាត្រា ២
- សិទ្ធិកុមារ មាត្រា ៣៧(ក)
- សិទ្ធិនយោបាយ មាត្រា ៧
- សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស មាត្រា ៥
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១២

៥- ប្រសិនបើចៅក្រមស៊ើបអង្កេតសំរេចឃុំខ្លួនអនីតិជន នោះចៅក្រមស៊ើបអង្កេត ត្រូវជូនដំណឹងអំពីសេចក្តីសំរេចឃុំខ្លួន សិទ្ធិសុំអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នទៅអនីតិជន ឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជន ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៩
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤
- សិទ្ធិកុមារ មាត្រា ៣៧(ឃ)

៦- ព្រះរាជអាជ្ញា ត្រូវចាត់ទុកជាចំបងចំពោះផលប្រយោជន៍របស់អនីតិជន នៅពេលសំរេចប្តឹង ឬមិនប្តឹងឧទ្ធរណ៍លើដីកាសំរេចមិនឃុំខ្លួន (ដាក់ឱ្យនៅក្រៅឃុំ) ឬដីកាសំរេចអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នរបស់ ចៅក្រមស៊ើបអង្កេត ចំពោះអនីតិជន។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៩
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤
- សិទ្ធិកុមារ មាត្រា ៣.១ - ៣៧(ខ)

៧- សំណុំរឿងក្តីអនីតិជន ត្រូវតែលើកយកមកចាត់ការជាអាទិភាព ហើយសំណុំរឿងក្តីអនីតិជន ដែលជនជាប់សង្ស័យជាអនីតិជនកំពុងជាប់ឃុំឃាំងជាបណ្តោះអាសន្ននោះ ត្រូវលើកយកមកចាត់ការជាអាទិភាពបំផុត ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣) - ៣៧(ឃ) - ៤០.២(ខ)(៣)
- សិទ្ធិនយោបាយ មាត្រា ១០.២(ខ)

៨- ការសាកសួរ(សម្ភាសន៍)លើជនជាប់សង្ស័យជាអនីតិជន ត្រូវធ្វើឡើងជាសំងាត់ និងក្នុងកន្លែងដោយឡែកពីនីតិជន ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៧)

៩- មេធាវី ឬឪពុកម្តាយ អាណាព្យាបាល ឬទាំងមេធាវី និង ឪពុកម្តាយ អាណាព្យាបាល ត្រូវមានវត្តមានក្នុងពេលធ្វើការសាកសួរ(សម្ភាសន៍) ជនជាប់សង្ស័យជាអនីតិជន ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ៧៦

- សិទ្ធិកុមារ ៤០.២(ខ)(៣)

១០- ចៅក្រមស៊ើបអង្កេត ត្រូវធ្វើការសាកសួរ(សម្ភាសន៍)ដោយខ្លួនឯងផ្ទាល់ ដោយមានក្រឡាបញ្ជីជាអ្នកធ្វើកំណត់ហេតុអមផង ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ៧៥ - ៧៦ - ៧៧- ៨១

១១- ការសាកសួរ(សម្ភាសន៍) គួរជៀសវាងការប្រើសំណួរនាំមុខ ការបញ្ចុះបញ្ចូល គំរាមកំហែង និងការបំភិតបំភ័យ ។ ការទំនាក់ទំនងនានាក្នុងដំណើរការសាកសួរ(សម្ភាសន៍) ត្រូវធ្វើឡើងក្នុងកិរិតដែលកុមារងាយយល់ ។

- រដ្ឋធម្មនុញ្ញ មាត្រា ៧៨
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៤.៣
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៤)
- សិទ្ធិនយោបាយ ១៤.៣(ឆ)

១២- បន្ទាប់ពីការសាកសួរ(សម្ភាសន៍)ចប់ភ្លាម កំណត់ហេតុសាកសួរ(សម្ភាសន៍)ត្រូវអានឡើងវិញឱ្យ អនីតិ-ជននោះស្តាប់ ហើយឱ្យផ្តិតមេដៃ។ ប្រសិនបើមានវត្តមានឪពុកម្តាយ អាណាព្យាបាល មេធាវី ចៅក្រមស៊ើបអង្កេតគប្បីឱ្យឪពុកម្តាយ អាណាព្យាបាល មេធាវីរបស់អនីតិជននោះ ចូលរួមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុសាកសួរ (សម្ភាសន៍) ផងដែរ ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

១៣- ចៅក្រមស៊ើបអង្កេតមិនត្រូវអនុញ្ញាតឱ្យមានការផ្សព្វផ្សាយរឿងក្តីអនីតិជន ដោយពុំមានច្បាប់អនុញ្ញាតិឡើយ ។

- ច្បាប់សារពត៌មាន ៤ - ៥ - ១៥
- សិទ្ធិកុមារ មាត្រា ១៦ - ៤០.២(ខ)(៧)
- សិទ្ធិនយោបាយ មាត្រា ១៤.១

ប្រទេសកម្ពុជាបានចុះហត្ថលេខាទទួលស្គាល់ អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៩២។ រដ្ឋធម្មនុញ្ញ មាត្រា ៣១ និង ៤៨ ចែងថា ប្រទេសកម្ពុជាទទួលស្គាល់ និងគោរពអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការពារសិទ្ធិកុមារ ដូចដែលមានចែងក្នុងអនុសញ្ញានោះ។ ការដែលបកស្រាយថា ច្បាប់ឆ្នាំ ១៩៩៩ ដែលចែងជាទូទៅនោះ គឺមិនបានលុបចោលសំណៅយោងជាក់លាក់អំពីអនីតិជន ដែលមានចែងក្នុងច្បាប់ ឆ្នាំ ១៩៩២ នោះទេ គឺមានន័យថា វាមានលក្ខណៈស្របគ្នាទៅនឹងគោលការណ៍ មាត្រា ៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលការឃុំខ្លួនអនីតិជន ត្រូវធ្វើឡើងតែក្នុងជំរើសចុងក្រោយប៉ុណ្ណោះ និងសំរាប់រយៈពេលខ្លីសមរម្យមួយ។

១៦- ប្រសិនបើចៅក្រមស៊ើបអង្កេត ធ្វើសេចក្តីសន្និដ្ឋានថា អនីតិជននោះ មានអាយុក្រោម ១៣ ឆ្នាំ ចៅក្រមស៊ើបអង្កេត អាចចេញដីកាសំរេចលើកលែងចោទប្រកាន់។ ជានិច្ចកាល ចៅក្រមស៊ើបអង្កេតគួរផ្តល់ប្រយោជន៍នៃវិមតិសង្ស័យនេះ ទៅអនីតិជន ក្នុងនោះដូចជាការរកឃើញនូវអាយុផ្ទុយគ្នា ក្នុងដំណាក់កាលផ្សេងៗនៃនីតិវិធី។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩០
- សិទ្ធិកុមារ មាត្រា ៤០.៣(ក)
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤.៥
- សិទ្ធិនយោបាយ មាត្រា ១៤.៤
- រដ្ឋធម្មនុញ្ញ មាត្រា ៣៨

### ឃ- សេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ដើម្បីបញ្ជូនសំណុំរឿងទៅចៅក្រមជំនុំជម្រះ

១- ព្រះរាជអាជ្ញា ត្រូវធ្វើសេចក្តីសំរេចអំពីសេចក្តីសន្និដ្ឋានចោទប្រកាន់ស្ថាពរ របស់ខ្លួនឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩០
- សិទ្ធិកុមារ មាត្រា ៣.១

២- បន្ទាប់ពីព្រះរាជអាជ្ញាបានទទួលដីកាសំរេចលើកលែងចោទប្រកាន់ លើជនជាប់សង្ស័យជាអនីតិជនពី ចៅ-ក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា ត្រូវពិចារណាអំពីផលប្រយោជន៍ជាសំខាន់របស់កុមារមុនពេលប្តឹងឧទ្ធរណ៍នឹងដីកាសំរេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបអង្កេតនោះ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩០
- សិទ្ធិកុមារ មាត្រា ៣.១

## ខ ~ ដំណាក់កាលសវនាការ របស់ចៅក្រមជំនុំជម្រះ

១- សំណុំរឿងក្តីអនីតិជន ចៅក្រមជំនុំជម្រះ ត្រូវលើកយកមកចាត់ការជាអាទិភាព ហើយសំណុំរឿងក្តីអនីតិជន ដែលជនជាប់ចោទជាអនីតិជនកំពុងជាប់ឃុំឃាំងជាបណ្តោះអាសន្ននោះ ចៅក្រមជំនុំជម្រះ ត្រូវលើកយកមកចាត់ការជាអាទិភាពបំផុត។

- សិទ្ធិកុមារ មាត្រា ៣.១ - ៣៧(ឃ) - ៤០.២(ខ)(៣)
- សិទ្ធិនយោបាយ មាត្រា ១០.២(ខ)

២- ត្រូវគោរពទៅតាមរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងច្បាប់ សំរាប់អនីតិជន។

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១៤
- ច្បាប់ឆ្នាំ ១៩៩៩ ស្តីពីរយៈពេលឃុំខ្លួនបណ្តោះអាសន្ន មាត្រា ១។

៣- នៅពេលដែលតុលាការ ពិចារណាបង្វិលសំណុំរឿងទៅចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាវិញ ដូចដែលមានចែងក្នុងមាត្រា ១០៦ ឬ១០៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ជាបឋមតុលាការគប្បីសំរេចដោយមានការពិចារណាទៅលើផលប្រយោជន៍របស់កុមារជាមុនសិន។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១០៦ - ១០៧
- សិទ្ធិកុមារ មាត្រា ៣.១

៤- ចៅក្រមជំនុំជម្រះ ត្រូវតែរកមេធាវីឱ្យអនីតិជនណាដែលគ្មានទីពឹង ។ ប្រសិនបើច្បាប់តម្រូវឱ្យរក មេធាវី ដំណើការផ្សេងៗ គប្បីផ្អាកសិន ដើម្បីឱ្យអនីតិជនអាចទទួលបាននូវមេធាវី ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៥ - ៧៦
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ១០
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

៥- អនីតិជន ត្រូវទទួលបានពេលវេលាគ្រប់គ្រាន់ សំរាប់រៀបចំសំណុំរឿងរបស់ខ្លួន ដើម្បីឆ្លើយដោះសារនៅចំពោះមុខតុលាការ ។

- សិទ្ធិនយោបាយ មាត្រា ១៤.៣(ខ)

៦- ការបើកសវនាការរឿងក្តីអនីតិជន អាចធ្វើឡើងជាសំងាត់ ដោយគោរពទៅតាម ផលប្រយោជន៍របស់អនីតិជន ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១២៩
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៣
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)
- សិទ្ធិនយោបាយ មាត្រា ១៤.១

៧- ចំពោះសវនាការរួមគ្នារវាង នីតិជន និងអនីតិជនដែលជាជនជាប់ចោទ គួរធ្វើជាសំងាត់ ប្រសិនបើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់អនីតិជន ។

៨- ឪពុកម្តាយ អាណាព្យាបាល មេធាវីរបស់អនីតិជន មានសិទ្ធិចូលរួមគ្រប់ដំណាក់កាលនៃនីតិវិធីដំណើរការរឿងក្តី ប្រសិនបើគ្មានការប៉ះពាល់ដល់ផលប្រយោជន៍របស់អនីតិជនទេ ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

៩- នៅពេលចាប់ផ្តើមបើកសវនាការ អនីតិជនត្រូវទទួលបានការឱ្យដំណឹងអំពីសិទ្ធិទាំងឡាយដូចខាងក្រោមនេះ:-

ក- សិទ្ធិទទួលបានការឱ្យដំណឹងអំពី បទចោទប្រកាន់

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(២)

ខ- សិទ្ធិមានវត្តមាននៅគ្រប់ឱកាសជំនុំជំរះ

- សិទ្ធិកុមារ មាត្រា ១២
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១០៨ - ១១១
- សិទ្ធិនយោបាយ ១៤.៣(ឃ)

គ- សិទ្ធិទទួលបានជាជនឥតទោសរហូតដល់តុលាការសំរេចសេចក្តីជាស្ថាពរ

- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ២៥
- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(១)
- សិទ្ធិនយោបាយ មាត្រា ១៤.២
- សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស មាត្រា ១១

ឃ- សិទ្ធិមានមេធាវី

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៥ - ៧៦
- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

ង- សិទ្ធិមិនទាន់ឆ្លើយដោយគ្មានមេធាវី

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៤)
- សិទ្ធិនយោបាយ មាត្រា ១៤.៣(ឆ)

ច- សិទ្ធិចូលរួមរបស់ឪពុកម្ដាយ អាណាព្យាបាល ក្នុងដំណើរការរឿងក្ដី ប្រសិនបើមិនផ្ទុយនឹងផលប្រយោជន៍របស់កុមារទេ ។

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៣)

ឆ- សិទ្ធិមានអ្នកបកប្រែភាសា ប្រសិនបើចាំបាច់

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៦)
- សិទ្ធិនយោបាយ ១៤.៣(ច)

ជ- សិទ្ធិបដិសេធផ្ដល់សក្ខីកម្ម ឬសារភាពកំហុស

- សិទ្ធិកុមារ មាត្រា ៤០.២(ខ)(៤)
- សិទ្ធិនយោបាយ មាត្រា ១៤.៣(ឆ)
- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៥

ឈ- សិទ្ធិបង្ហាញសាក្សី និងបង្ហាញភស្ដុតាង ព្រមទាំងសួរសំណួរផ្សេងៗតាមរយៈចៅក្រម

- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣២

ញ- សិទ្ធិជៀសផុតពី អំពើទារុណកម្ម អំពើហិង្សា ឬការគំរាមគំហែងផ្សេងៗ

- រដ្ឋធម្មនុញ្ញ មាត្រា ៣៨
- អនុសញ្ញាស្ដីពីការប្រឆាំងនឹងទារុណកម្ម មាត្រា ២
- សិទ្ធិកុមារ មាត្រា ៣៧(ក)
- សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស មាត្រា ៥
- ច្បាប់ព្រហ្មទណ្ឌអន្ដរកាល មាត្រា ១២
- ប្រកាសរួមស្ដីពីការហាមប្រើប្រាស់ខ្នោះដៃ លេខ:២៧៨-របឌ៣
- នីតិវិធីពន្ធនាគារ(២០០១) លេខ:២១
- សិទ្ធិកុមារ មាត្រា ៣៧(ក)

១២- ប្រសិនបើព្រះរាជអាជ្ញាបានផ្តល់យោបល់ដល់ចៅក្រមជំនុំជម្រះនូវទោសដែលចៅក្រមជំនុំជម្រះគួរតែសំរេចនោះ ព្រះរាជអាជ្ញា អាចស្នើសុំឱ្យដាក់ទណ្ឌកម្មណាដែលមានលក្ខណៈសមស្របទៅនឹងបទល្មើស និងស្ថានភាពរបស់អនីតិជន ក្នុងគោលដៅអប់រំកសាងខ្លួនឱ្យបានល្អប្រពៃឡើងវិញ។

- សិទ្ធិកុមារ មាត្រា ៣.១
- សិទ្ធិនយោបាយ មាត្រា ១៤.៤

១៣- តុលាការត្រូវពិចារណាទៅលើរបាយការណ៍គួរឱ្យទុកចិត្តបានរបស់ភ្នាក់ងារផ្សេងៗ ដូចជា ភ្នាក់ងារការពារអនីតិជន ឬអ្នកបំរើការងារសង្គម--- ដែលបានផ្តល់ដោយភាគី ឬមេធាវី---។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១២៥ - ១៣៥

១៤- ចៅក្រមជំនុំជម្រះ គួរពិចារណាអំពីការផ្តន្ទាទោសតាមជំរើសផ្សេងៗ មុនពេលសំរេចផ្តន្ទាទោសដាក់ពន្ធនាគារចំពោះអនីតិជន។ ការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារ គឺជាវិធានការចុងក្រោយបំផុតរបស់ចៅក្រមជំនុំជម្រះ។

- សិទ្ធិកុមារ មាត្រា ៣៧ (ខ)

១៥- ចៅក្រមជំនុំជម្រះ គួរធ្វើការសំរេចផ្តន្ទាទោស ដែលមានលក្ខណៈសមស្របទៅនឹងបទល្មើស ដែលបានប្រព្រឹត្ត និងពិចារណាទៅលើស្ថានភាពនានា នៃបទល្មើស និងជនជាប់ចោទ។

- សិទ្ធិកុមារ ៣.១ និង ៤០.១ - ៤០.៤
- សិទ្ធិនយោបាយ ១៤.៤
- សិទ្ធិកុមារ ៣៧(ក) និង (ខ)

១៦- ចៅក្រមជំនុំជម្រះ ត្រូវប្រាប់អំពីសិទ្ធិប្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសំរេចរបស់តុលាការដល់អនីតិជន និងឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជន។

- ច្បាប់ស្តីពីការចាត់តាំង និងដំណើរការរបស់សាលាជម្រះក្តី មាត្រា ៨
- សិទ្ធិកុមារ មាត្រា ៤០.២ (ខ)(៥)

- សិទ្ធិនយោបាយ មាត្រា ១៤.៥
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥៥
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៤

១៧- តុលាការត្រូវតំកល់ផលប្រយោជន៍សិទ្ធិឯកជន កិត្តិយស សេចក្តីថ្លៃថ្នូរ របស់អនីតិជនជាចំបង មុននឹងអនុញ្ញាតឱ្យមានការផ្សព្វផ្សាយរឿងក្តីព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងអនីតិជន ។

- ច្បាប់សារពតិមាន មាត្រា ៤ - ៥ - ១៥
- សិទ្ធិកុមារ មាត្រា ១៦ - ៤០.២(ខ)(៧)
- សិទ្ធិនយោបាយ មាត្រា ១៤.១

១៨- កំណត់ហេតុនានារបស់តុលាការស្តីពី រឿងក្តីអនីតិជនត្រូវរក្សាទុកជាឯកសារសំងាត់ ។

- សិទ្ធិកុមារ ១៦ - ៤០(ខ)(៧)

## ច ~ ចំពោះការនាំខ្លួនអនីតិជន

ចំពោះករណីបទឧក្រិដ្ឋ អនីតិជនអាចទទួលការដាក់ខ្នោះដៃបាននៅពេលនាំខ្លួន ប៉ុន្តែមិនអាចដាក់ខ្នោះបានទេនៅពេលធ្វើការសាកសួរ(សម្ភាសន៍) ដោយចៅក្រមស៊ើបអង្កេត និងក្នុងពេលសវនាការ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣០
- នីតិវិធីពន្ធនាគារ(២០០១) លេខ ២១ (កថាខ័ណ្ឌ ៤.២.១) និង លេខ ២៣ (កថាខ័ណ្ឌ ៤.១.២)
- ប្រកាស លេខ ២១៧ ចុះថ្ងៃទី ៣១ មីនា ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការគ្រប់គ្រងពន្ធនាគារ មាត្រា ៤ ផ្នែកទី ៥ (ក) ដល់ (ច) និង ផ្នែក ២៥ (ក) ដល់ (គ) ។

ក្រោយពីទទួលបានសេចក្តីណែនាំនេះ សូមមន្ត្រីអនុវត្តច្បាប់ដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់អនុវត្ត នូវគោលការណ៍ និងបទបញ្ញត្តិទាំងនេះឱ្យបានសំរេច និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ ក្រសួងយុត្តិធមិសង្ឃឹមយ៉ាងមុត

មាំថា មន្ត្រីអនុវត្តច្បាប់ទាំងអស់ច្បាស់ជាយកចិត្តទុកដាក់ខិតខំអនុវត្តតាមសេចក្តីណែនាំនេះ ដើម្បីចូលរួមអនុវត្តគោលនយោបាយកំណែទម្រង់ច្បាប់ និងតុលាការឱ្យទទួលបានជោគជ័យ ជូនរាជរដ្ឋាភិបាលពុំខានឡើយ ។

អង្គ វង្សវឌ្ឍានៈ

<u>ចំលងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- ក្រសួងសុខាភិបាល

  ដើម្បីចម្លងផ្សព្វផ្សាយ
- ឯកសារ
- កាលប្បវត្តិ